# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំទី ២៣ វិច្ឆិកា លេខ ១១

ព. ស. ២៤៩៤ – គ. ស. ១៩៥១

# សេចក្ដីជូនដំណឹងពិសេស

## ពីក្រុមពុទ្ធសាសនបណ្ឌិត្យ

សៀវភៅ សត្តបរិត្ត—ទ្វាទសបរិត្ត និង បាតិមោក្ខសង្ខេប ដែលជាវអស់ពីលើកមុន, ឥឡូវនេះ បានបោះពុម្ពឡើងទៀត ជាច្រើនច្បាប់ មានសម្រាប់ជាវដល់បណ្ដាជនទូទៅ ។

ដូច្នេះ, អស់លោក-អ្នកពុទ្ធបរិស័ទ ដែលមានបំណងរង់ចាំជាវសៀវភៅនេះ សូមអញ្ជើញចូលទៅជាវតាមត្រូវការ នៅក្រុមពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ។

សៀវភៅ សត្តបរិត្ត-ទ្វាទសបរិត្ត ថ្លៃ ១៩រ.០០ ក្នុង ១ ក្បាល ។

— បាតិមោក្ខសង្ខេប — ៧រ.៥០ ក្នុង ១ ក្បាល ។

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយជំណឿខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ


| ផ្នែកសាសនា | បញ្ជីរឿង | ទំព័រ |
|---|---|---|
| ពុទ្ធសាសនានិងគ្រិស្តសាសនា (សន្និសិទលោកវេជ្ជបណ្ឌិតមីគូត៍) (តមក)... | លោកប៉ាយ-ប៊ុក ......... | ៨០៣ |
| ពន្លឺអាស៊ីទ្វីប (តមក)........... | លោកប៉ាយ-ប៊ុក ......... | ៨០៨ |
| ទិដ្ឋធម្មិកកថា.................. | ព្រះអរិយកស្សប កែវ-អ៊ួច ... | ៨១២ |
| **ផ្នែកអក្សរសាស្ត្រ** | | |
| ប្រស្នាពិធីបុណ្យខ្មោច ............ | លោក ប៊ូ-ប៊ូ .......... | ៨១៨ |
| រឿងស្ដេចត្រី .................. | លោកផេង-ជ្រីវ .......... | ៨៣១ |
| ការបណ្ដុះនិស្ស័យ (តមក)........ | ព្រះមហាឧត្តមវិជ្ជា ប៊ុង-ប៉ុម ... | ៨៤៣ |
| រឿងសាមកុក (តមក)........... | ឧកញ៉ា ឡូ-កន ......... | ៨៥១ |
| ព្រះរាជពង្សាវតារប្រទេសកម្ពុជា (តមក).. | ឧកញ៉ា ឈឹម-ក្រសេម..... | ៨៦១ |
| រឿងអារក្សថ្លៃងរ៉េងម្ដៃប្រាំ (តមក).... | លោកសាង-សាភ៊ត....... | ៨៦៤ |
| **កំណត់ទីនប្រវត្តិការណ៍** | | |
| អនិច្ចធម្មនៃព្រះទេពមុនី យូរ-ប៉ុណ្ណ..... | ព្រះទេពសត្ថា ស្ហូរ-ហាយ ... | ៨៧១ |



មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃជាវ ១៤៥ រ.០០

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

## TABLE DES MATIÈRES


PARTIE RELIGIEUSE — Pages

| | | |
|---|---|---|
| Bouddhisme et Christianisme (Conférence du Docteur A. Migot) (suite) | M. RAY-BUC . . . . . . . . . | 803 |
| La Lumière de l'Asie (suite) . . . | M. RAY-BUC . . . . . . . . . . | 808 |
| Dithidhammikal atha . . . . . . . . . | Vén. KEO-OUCH . . . . . . | 812 |

PARTIE LITTERAIRE

| | | |
|---|---|---|
| Différentes rites funéraires . . . . . | M BOU-PO . . . . . . . . . . | 818 |
| Histoire du Roi-Poisson Contes et Légendes roumains) . . . . . . . | M. PHENG CHRIEU . . . . . . | 831 |
| Education morale (suite) . . . . . . . | Vén. PENG-PAM . . . . . . | 843 |
| Histoire de SAMKOK (suite) . . . . | Oknha NOU KAN . . . . . . | 851 |
| Histoire du Royaume du Cambodge (suite) . . . . . . . . . . . . . . . . | Oknha CHHIM-KRASEM . . | 861 |
| Les vingt-cinq récits du mauvais Génie (suite). . . . . . . . . . . . . | M. SANG-SAVATH . . . . . . | 864 |

NOTES ET CHRONIQUES

| | | |
|---|---|---|
| Décès de Brah Debamuni You-Ponn . . . . . . . . . . . . . . . . . . | Vén. SO-HAY . . . . . . . | 871 |


Prix d'abonnement annuel comprenant 12 numéros: 145$00

# ពុទ្ធសាសនា និង គ្រិស្តសាសនា

## សន្និសីទលោកវេជ្ជបណ្ឌិត មីគូត៌

លោក ក៉យ-ប៊ុក គ្រូមការ នៅពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ប្រែពីទស្សនាវដ្ដី " ហ្វ្រង់ស-អាស៊ី " ខែមិថុនា ឆ្នាំ ១៩៥០

(តមក)

---

អ្នកទាំងពីររស់នៅដោយសីលធម៌តែមួយដូចគ្នា ប្រព្រឹត្តធុតង្គដូចគ្នា, ដើរតាមផ្លូវធម៌ដូចគ្នា, មានបំណងទៅកាន់អហេតុកធាតុដូចគ្នា ហើយមានសភាពរលាយមូលបូលគ្នាតែមួយ ប្រៀបដូចទឹកទន្លេជាច្រើន ដែលហូរមកពីទ្វីបផ្សេងៗ ប្រមូលបូលទៅកាន់មហាសាគរតែមួយ ។

ខ្ញុំខំព្យាយាមបង្ហាញលោកអ្នកអំពីពួកអ្នកបច្ចិមទ្វីប ដែលមានគំនិតយល់មិនបានសព្វគ្រប់ ហើយខ្វែងគំនិតចំពោះព្រះពុទ្ធសាសនា ។ យើងបានឃើញថា សីលធម៌ខាងព្រះពុទ្ធសាសនាមានសភាពដ៏ឧត្ដម ជាងសីលធម៌ខាងគ្រិស្តសាសនា ហើយសីលធម៌នោះអាចមានពលភាពឡើងទៅដល់កំពូលនៃព្រហ្មវិហារនិងពលីកម្ម ។ យើងបានឃើញជាញឹកញយនូវពួកគ្រែជាង (គ្រិស្តសាសនិកជន): ពិតមែនតែពួកនេះទទួលស្គាល់នូវសីលធម៌នៃព្រះពុទ្ធសាសនាថាមានសភាពល្អស្អាត, តែនៅយល់ថាព្រះពុទ្ធសាសនា ជាសាសនាមានសភាពមិនបានពេញលក្ខណៈ,

ហើយថាលុះតែត្រូវយកគ្រិស្តសាសនាមកអនុវត្តផង ទើបបានជាសាសនាពេញលេញ ។ ដែលពួកនេះយល់ដូចនេះដោយសារការពិនិត្យឃើញថាព្រះពុទ្ធសាសនាមិនព្រមទទួលស្គាល់ព្រះអាទិទេព ( អាទិទេវមិច្ឆាគតិ Athéisme) និងមិនព្រមអនុម័តនូវព្រះអាទិទេពថាមានសភាពពិត ។ យើងបានពិនិត្យឃើញថាដែលស្របនឹងយោបល់នេះ ចំពោះព្រះពុទ្ធសាសនាខាងហីនយានមិនសូវជាត្រូវចំពិតណាស់ទេ, បើតាមលទ្ធិខាងមហាយាន មតិនេះគឺមានសភាពខុសពេញលក្ខណៈ ។ បើគេពិនិត្យព្រះពុទ្ធសាសនាទាំងមូលសព្វគ្រប់ទៅ គេអាចឃើញបានថាពេលដែលព្រះពុទ្ធសាសនាកំពុងវិវត្តក្នុងពិភពលោក, ការបុច្ឆា - វិសជ្ជនាអំពីអាទិទេវគតិ នឹងបរមត្ថវិជ្ជាដែលមានសំដែងក្នុងគម្ពីរព្រះត្រៃបិដកត្រង់កន្លែងខ្លះ ឃើញថាបញ្ហាមានអត្ថដ៏គម្ភីរភាព រហូតដល់បញ្ហាអហេតុកធាតុនឹងព្រះអាទិទេព, ហើយគេអាចពិនិត្យទៅឃើញថា គ្មានសាសនាណាពណ៌នាអំពីរឿងនេះ ឲ្យច្បាស់លាស់ជាងព្រះពុទ្ធសាសនានេះទៀយ ។ បើតាមយោបល់របស់ខ្ញុំ បញ្ហាក្នុងអហេតុកធាតុខាងព្រះពុទ្ធសាសនា គេយកមកដោះស្រាយខាងផ្លូវប្រាជ្ញា ជាញឹកញាប់ជាងខាងគ្រិស្តសាសនា ។ ព្រោះហេតុដូចនេះ, ព្រះអាទិទេព តាមគម្ពីរគ្រិស្តសាសនា (Bible) ថាមានបុគ្គលិកលក្ខណៈជាមនុស្សសាមញ្ញ Vêtement anthropomophique) ប្រៀបដូចគ្នានឹងព្រះអាទិទេព ដែល

មានរូបទ្រង់ទាមលក្ខណៈផ្នែកខាងព្រហ្មញ្ញសាសនា ។ ក្នុងរឿងនេះ, មានតែប្រទេសឥណ្ឌាតែមួយទេ ដែលអាចពិនិត្យទៅឃើញអហេតុកជាតុមួយ គ្មានសភាពប្រែប្រួល, នៅពីលើព្រះរូបអាទិទេពដែលជាទីគោរព ហើយជារូបនិមិត្តផ្សាយចេញ ដោយឥទ្ធិវិធីអំពីអហេតុកជាតុ ។

គេអាចពោលអំពីព្រះពុទ្ធសាសនាតទៅទៀត ថាជាសាសនាមិនមែនប្រព្រឹត្តបានដោយងាយឡើយ គឺជាសាសនាគេលំបាកនឹងប្រតិបត្តិតាមជាងគ្រិស្តសាសនា (សាសនាកាតូលិក) ។ ពិតមែនតែសាសនាទាំងអស់មានវិធីប្រតិបត្តិជាសាមញ្ញលក្ខណៈងាយបំផុត គឺគ្រាន់តែប្រព្រឹត្តទៅតាមសទ្ធានិងតាមវិធីប្រតិបត្តិជាពាហិរភាព ។ បើតាមពិត ការប្រព្រឹត្តធម៌ជាសុក្រិតភាព ត្រូវមានការព្យាយាមយ៉ាងម៉ឺងម៉ាត់ ដោយចិត្តក្លាហានអង់អាច ។

ខ្ញុំចង់ប្រៀបធៀបគ្នាខ្លះសាសនាទាំងពីរ អំពីវត្ថុបំណងដែលសាសនានេះបានកំណត់ទុក, តើសាសនាទាំងពីរបញ្ញត្តិឲ្យសាវ័កប្រព្រឹត្តយ៉ាងណាខ្លះ? ។ ចំណែកខាងសាសនាកាតូលិក សន្តភាព (Sainteté) ជាឧត្តម-គតិចំពោះបុគ្គលមានភាគតិច; សន្តភាពនេះ មិនមែនបញ្ញត្តឲ្យទៅដល់ពួកសាមញ្ញជនទាំងអស់ទេ, វត្ថុបំណងនៃសាសនានេះ គឺប្រាថ្នាទៅកាន់សុគតិដោយប្រព្រឹត្តជីវភាពខ្លួន ទៅតាមបទបញ្ញត្តិនៃព្រះអាទិទេពនិងវត្តប្រតិបត្តិ ។ កម្មវិធីនេះ នាំឲ្យមានការប្រឹងប្រែង, តែការ

ប្រព្រឹត្តិនោះមានពួកសទ្ធបុគ្គល (Croyants) ដោយភាគច្រើនអាចធ្វើបានដោយងាយ, ហើយមានសាវ័កខ្លះអាចប្រតិបត្តិឲ្យបានសម្រេចតាមបំណង ។

បំណែកខាងពួកគ្រិស្តសាសនិកជន បើចង់ដោះខ្លួនឲ្យរួចពីទុក្ខទាំងពួង មិនចាំបាច់ធ្វើខ្លួនឲ្យជាសទ្ធបុគ្គលទេ, ឯពួកពុទ្ធសាសនិកជនក៏ត្រូវតែសម្រេចខាងមិនបាន នូវសម្មាសម្ពោធិញ្ញាណ គឺការត្រាស់ដឹងជាព្រះពុទ្ធមួយព្រះអង្គ ដើម្បីនឹងចេញចាកតណ្ហា ។ កិច្ចដែលត្រូវធ្វើនេះជាកិច្ចតឹងរឹងពន់ពេក ។ គេអាចប្រព្រឹត្តធម៌ទៅតាមលំអាន ឬប្រាថ្នាឲ្យបានសម្រេច ចំពោះជាតិនេះ ដូចជាពួកយោគាវចរខាងប្រទេសទីបេត៍ ជាសាវ័កខាងផ្លូវត្រង់ (Sentiredirect) ឬធ្វើឲ្យបានចម្រើនបន្តិចម្តងៗ ជាច្រើនជាតិ ចំពោះផ្លូវសាមញ្ញ ។ ធ្វើយ៉ាងដូចនេះ គ្រាន់តែបន្សុះបន្សយនូវវត្តប្រតិបត្តិប៉ុណ្ណោះ; តែដល់អវសានជាតិ ត្រូវតែព្យាយាមដោយក្លាហាន ប្រព្រឹត្តនូវធម៌ជាន់ខ្ពស់ ដើម្បីនឹងសម្រេចនូវពុទ្ធភូមិ ។

រឿងរ៉ាវទាំងប៉ុន្មាន ខ្ញុំបានពណ៌នាហើយ, តែបើខ្ញុំពោលថាខាងបូព៌ាទ្វីបមានសុទ្ធតែរបស់ល្អ, ខាងបច្ចិមទ្វីបមានសុទ្ធតែរបស់អាក្រក់ នោះគេនឹងទុកខ្ញុំជាពួកអធម្មយុត្តិកបុគ្គល ។ តាមពិតមនុស្សនៅគ្រប់ទីកន្លែង ទោះបីធ្លាក់ចុះទៅកាន់សេចក្តីលំបាក ឬឡើងទៅកាន់កិត្តិយសដ៏ប្រសើរ ក៏គេទុកជាមនុស្សជាតិដូចគ្នា ។ ពួកខាងគ្រិស្តសាសនាដែល

ពោលថាកិត្តិសព្ទនៃសាសនានេះមកពីព្រះគ្រិស្ត ។ តែច្រើនជាអ្នកមិនប្រព្រឹត្តតាមបទបញ្ញត្តិព្រះគ្រិស្តទេ ។ ចំណែកខាងព្រះពុទ្ធសាសនាដូនកាលត្រូវប្រែប្រួលនូវបទបញ្ញត្តិជាច្រើនកន្លែងដែរ, តែគេអាចដោះស្រាយនូវបញ្ហានេះ ដែលមានសភាពស្មុគ្រស្មាញទូលាយ ជាអនេកប្បការមិនចេះចប់មិនចេះដាច់ស្រេច ។

ការពិនិត្យដើមឈើដោយយកផ្លែជាប្រមាណ ប្រហែលជាបញ្ហាមួយអាចនាំមនុស្សឲ្យដោះស្រាយបានដោយងាយ ។ តើនៅបច្ឆិមទ្វីប, ព្រះគ្រិស្តសាសនាដែលផ្សាយបានខ្ពស់តែស្រមៃកហើយ ឃើញបានផលយ៉ាងណាទៅ? ចំពោះលោកគត, ពិតមែនតែមានសទ្ធបុគ្គលជាច្រើន, តែនៅតែក្ដៅដួងវិញ្ញាណរបស់ខ្លួនចំពោះប្រជាជាតិប្រកបដោយពលកាត, ពេញចិត្តខាងសង្គ្រាម មិនសូវមានចិត្តសន្តោសមេត្តា, មានតែសេចក្ដីប្រាថ្នាប្រយោជន៍ផ្ទាល់ខ្លួន, ចំពោះសង្គមមានតែអយុត្តិធម៌ ដែលមានប្រាជ្ញារលុបរលាយដោយគ្រឿងចក្រសង្កត់សង្កិនជាខ្លាំងដែលមានគេនិយមតែគោរពទ្រព្យនិងវត្ថុពលគ្រៅ, អត្តទត្តភាពចំពោះបុគ្គលនិងប្រជាជាតិទាំងនេះ នាំឲ្យកើតសង្គ្រាមកាន់តែញឹកញយ, កាន់តែកាចសាហាវ ដែលមនុស្សបញ្ចេញនូវសភាវគតិដ៏ថោកទាបបំផុត; ដែលវិទ្យាសាស្ត្រគ្រាន់តែជាជំនួយក្នុងកិច្ចធ្វើទារុណកម្ម ។

(មានត)

# ពន្លឺអាស៊ីទ្វីប

## វគ្គទី ៣

La Lumière de l'Asie

## លោកស៊ឺរ-អេតវិង អារណុលត៍ តែង
## លោកវ៉ាយ-ប៊ុក ក្រមការ ប្រែរៀបរៀង

(តមក)

---

ព្រះនាងយសោធរាទ្រង់បានចាត់អស្វកោរិទ (Cavaliers) ៩ នាក់ ឲ្យទៅក្រាបទូលព្រះសម្ពុទ្ធ: "អញ, មាតារាហុល, មានបំណងជាខ្លាំង ចង់ឃើញព្រះភក្ត្រព្រះអង្គ ប្រៀបដូចហទយវត្ថុដែលតោរប៉ោងឡើង ដោយយល់តារាបូរព៌ពីក្រោយព្រះចន្ទដូចជាផ្កាអសោក (Asoka) ក្រពុំ រង់ចាំនៅជើងនារី,(១) បើព្រះស្វាមីអញ ទ្រង់រកកំណប់ទ្រព្យដែលបាត់ទៅហើយ ឃើញបានមកវិញ នោះអញនឹងសូមកំណប់ទ្រព្យនោះឲ្យរាហុលកុមារ, សម្រាប់ខ្លួនអញៗ នឹងតាមទារនូវព្រះអង្គលោកឲ្យបានជាស្វាមីវិញ" ៗ ពួកព្រះរាជវង្សសាក្យ: បាននាំគ្នាទៅតាមព្រះរាជបញ្ជាដោយរួសរាន់ ទៅដល់វេឡុវនុយ្យាន (ឧទ្យានឫស្សី) នៅពេលមួយដែល

---

១ ក្នុងរឿងរាមាយណៈថ្លែងថា នាងសីតាបានរត់ទៅពួននៅក្រោមគុម្ពោតដើម អសោក ក្នុងពេលដែលក្រុងរាពណ៍ទៅកំហែងចាប់ចង់នាង, តែនាងបានតស៊ូនឹងរាពណ៍ទាល់តែមានជោគជ័យក្នុងពេលនោះ, ហេតុនេះពួកស្រីហិណ្ឌូ ទើបគោរពដើមអសោកនេះណាស់ ។

ព្រះសម្មាសម្ពុទ្ធកំពុងសំដែងធម៌ទេសនា ។ ព្រះរាជវង្សទាំងនោះ ក៏ចូលទៅស្តាប់ព្រះធម៌ទេសនាដ៏ពីរោះនោះហើយ ក៏ភ្លេចនឹកដល់ព្រះរាជបណ្តាំ (សារលិខិត) នៃព្រះមហាក្សត្រិយ៍នឹងព្រះនាងដែលកំពុងព្រួយបារម្ភជាខ្លាំង ។ ពួកសាក្យៈទ្រង់ពុំតែព្រះសូរសៀងដ៏ពីរោះអស្ចារ្យរបស់ព្រះបរមគ្រូ, ព្រះហឫទ័យនៃទ្រង់ទាំងនោះស្ងប់ចុះ ដោយបានក្រេបនូវរសឈ្ងិតព្រះធម៌ដ៏ហូរចេញអំពីព្រះពុទ្ធឱស្ឋ សិងប្រកបដោយព្រះករុណា-ធិគុណ នឹងពុទ្ធានុភាព សុក្រិតភាព បរិសុទ្ធស្អាត, អ្នកស្តាប់ទាំងនោះអាចជ្រួតជ្រាបនូវធម៌គ្រប់យ៉ាង ។

បូរអ្នកឃើញ! ប្រៀបដូចកមារជញ្ជក់ទឹកផ្អែមក្នុងសំបុកដែលមានរសជាតិផ្អែមឆ្ងាញ់ ភ្លេចគិតនឹកដល់អ្វីៗទាំងអស់ ទោះបីជាយប់យន់អន្ធ-ការយ៉ាងណា ឬក៏មានភ្លៀងផ្គរយ៉ាងណាក៏ដោយ ពួកកមារអំបាលនោះក៏ខំតែជញ្ជក់យករសជាតិមធុរស ដែលកើតពីបុប្ផជាតិទាំងឡាយប៉ុណ្ណោះដូចម្តេចមិញ? ពួកអាមាត្យ[២] ដែលព្រះមហាក្សត្រិយ៍ត្រាស់ប្រើឲ្យទៅនិមន្តព្រះសម្មាសម្ពុទ្ធពេលនោះ បានផ្ទៀងសោតប្រសាទស្តាប់ព្រះសទ្ធម្មទេសនារបស់ព្រះអង្គដែលពីរោះចាប់ចិត្តជាបំផុត ក៏នាំឲ្យភ្លាំងភ្លេចព្រះរាជបញ្ជាការអស់ ហើយក៏នៅក្នុងសំណាក់ព្រះអង្គ មិនបានត្រឡប់នាំសេចក្តីទៅក្រាបទូលព្រះមហាក្សត្រិយ៍វិញ ក៏ដូច្នោះឯង ។

លំដាប់ពីនោះ ព្រះមហាក្សត្រិយ៍បានត្រាស់បង្គាប់ឲ្យឧទាយីដែលជាមន្ត្រីធំក្នុងព្រះបរមរាជវាំង ហើយជាសំណប់របស់ព្រះអង្គ ទាំងជា

កល្យាណមិត្តរបស់ព្រះសិទ្ធត្ថក្នុងកាលនៅជាកុមារផង ឲ្យទៅនិមន្ត ៗ ឧទាយីកាលចូលទៅក្នុងឧទ្យាននោះ បានបេះយកសំឡីកប្បាសមកបុកត្រចៀកខ្លួន ដើម្បីកុំឲ្យឮព្រះសទ្ធម្មទេសនារបស់ព្រះបរមគ្រូ ក្រែងនឹងខូចករណីយកិច្ចដូចពួកខ្ញុំមុន ៗ គ្រានោះឧទាយីបានក្រាបទូលតាមព្រះរាជសាររបស់ព្រះរាជបិតា និងព្រះនាងយសោធរា ៗ

ព្រះសម្មាសម្ពុទ្ធទ្រង់ឮនព្រះសារ ហើយមានព្រះបន្ទូលទៅកាន់ទីប្រជុំថា " យើងនឹងទៅក្នុងពេលឆាប់ៗនេះ ។ នេះគឺជាករណីយកិច្ចរបស់យើងផង ជាធុរៈរបស់យើងផង; នរណាក៏ដោយមិនត្រូវភ្លេចគោរពបុព្វ-បុរសដែលឲ្យកំណើតដល់ខ្លួន ដែលជាមធ្យោបាយសម្រាប់ពិចារណាចៀសវាងពីការរស់នៅក្នុងលោក ហើយនឹងរិះរកផ្លូវប្រាជ្ញាដែលឲ្យផុតពីសេចក្ដីស្លាប់ ដើម្បីឆ្ពោះទៅកាន់ព្រះនិព្វាន, បើគេប្រតិបត្តិត្រឹមត្រូវតាមច្បាប់ បើគេបោះបង់ចោលនូវបាបធម៌ពីអតីតជាតិ លែងប្រព្រឹត្តអំពើអកុសលក្នុងបច្ចុប្បន្នជាតិជាថ្មីថែមទៀត អាចទៅកាន់ព្រហ្មចរិយៈ ហើយនឹងសេចក្ដីអាណិតអាសូរដល់សព្វសត្វ ដែលជាដែននៃធម៌ព្រហ្មវិហារនោះ ៗ ចូរអ្នកទៅក្រាបទូលព្រះរាជបិតា និងព្រះនាងយសោធរាវិញថា: យើងនឹងធ្វើដំណើរទៅជួបព្រះរាជបិតា និងព្រះនាងជាមិនខាន! ៗ

កាលដំណឹងនេះជ្រួតជ្រាបទៅដល់ក្រុងកបិលពស្តុហើយ ប្រជាជននៅក្នុងកំឡុងក្រុងកបិលពស្តុ និងអ្នកនៅជិតខាងជុំវិញក្រុង បានប្រុង

ប្រៀបរៀបចំ ចាំទទួលព្រះរាជនុរសយ៉ាងរុងរឿង ៗ នៅក្រោងទ្វារខាងត្បូង គេបានសង់សាលាមួយ ប្រដាប់ដោយផ្កាកម្រង ទីងសំពត់ព្រែពណ៌ទៀត ប៉ាក់ដោយឌិនមាស; គេបានពាយនូវមែកក្រអូប នៃរុក្ខជាតិ "និម" (nim) ទីងមែកស្វាយដេរដាសពាសពេញផ្លូវ ហើយគេបានយកមុសស៊ុក្ខ (ថូស្បែកពពែញី) ដែលពេញទៅដោយទឹកអប់កំញានទឹងផ្កាម្លិះស្រោចស្រប់ សព្វទីព្រះរាជធានី ព្រមទាំងប្រដាប់ដោតទង់គ្រប់ទីកន្លែង ៗ

(មានត)

ចូរជួយខ្លួនអ្នក ទើបទេព្ដាជួយអ្នក

ជួយខ្លួនឯង ដោយប្រឹងប្រែង រៀនវិជ្ជា
ប្រឹងធម្មា សុចរិត ផ្ចិតនិស្ស័យ
ឲ្យកើតឈ្មោះ លាន់ពីរោះ ជាមនុស្សថ្លៃ
អ្នកកុំភ័យ! គង់មានថ្ងៃ ទេព្ដាជួយ ៗ
សុភាសិត សង្កត់ថា "ខ្លួនពឹងខ្លួន"
ពឹងគឺសួន ខំរករៀន ប្រៀនខ្លួនមួយ
ឲ្យបានបទ ជាក់ប្រាកដ អ្នកកុំព្រួយ!
ទេព្ដាជួយ ឲ្យជោគជ័យ ថ្លៃអនគ្ឃ ៗ

យូរ-អ៊ុន

ទិដ្ឋធម្មិកកថា

# ព្រះអរិយកស្សប កែវ-អ៊ុប វត្តបទុមវតី ភ្នំពេញ

ទេសនាផាក់វិទ្យុនៅថ្ងៃ ៨ កើតខែមិគសិរ ឆ្នាំកុរនព្វស័ក ព. ស. ២៤៩០
ត្រូវនឹងថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ១៩៤៧

## ន សិយា លោកវឌ្ឍនោ

"បុគ្គលមិនគប្បីធ្វើខ្លួន ឲ្យជាមនុស្សបង្អៀតលោកទេ" ។

ពេលនេះ អាត្មាភាពត្រូវវេនសំដែងធម្មទេសនាចែកជូនអស់លោកអ្នកស្ដាប់តាមវិទ្យុកម្ពុជា ។ អាត្មាភាពនឹងសំដែងទិដ្ឋធម្មិកធម៌ គឺធម៌ជាគ្រឿងនាំមកនូវផលប្រយោជន៍ដល់លោកក្នុងបច្ចុប្បន្នជាតិនេះ នឹងជាតិមុខ ដូចព្រះបាលីដែលមានមកក្នុងគម្ពីរខុទ្ទកនិកាយថា ន សិយា លោក-វឌ្ឍនោ អធិប្បាយសេចក្ដីថា មនុស្សយើងដែលកើតមកក្នុងលោកនេះ មិនត្រូវធ្វើខ្លួនឲ្យជាមនុស្សបង្អៀតលោកទេ ត្រូវធ្វើខ្លួនឲ្យជាមនុស្សសាងលោកឲ្យចំរើន ត្រូវមាននាទីសម្រាប់មនុស្សជាតិ សម្រាប់ប្រព្រឹត្តបដិបត្តិតាម គឺថាបើជាយកវាស ត្រូវនាំគ្នាប្រព្រឹត្តតាមភូមិយកវាស ៣ យ៉ាង ។ ឯភូមិយកវាស ៣ យ៉ាងនោះ គឺ :

១– បើជាអ្នកធ្វើស្រែចំការ ត្រូវតាំងចិត្តជាអ្នកឧស្សាហ៍ព្យាយាមខំតខំធ្វើការជានិច្ចកាល កុំគប្បីធ្វេសប្រហែសដោយសេចក្ដីខ្ជិលច្រអូសនឹងសេចក្ដីធុញទ្រាន់ឡើយ ព្រោះតាមទម្លាប់ខេមរជនយើង ច្រើនធ្វើការ

រកស៊ីគ្រាន់តែឲ្យល្មមមាត់ គ្រប់គ្រាន់កងគ្រួសារប៉ុណ្ណោះ មិនធ្វើឲ្យជាប្រយោជន៍ហួរហៀរជាសម្បត្តិនគរផង ហេតុដូច្នេះ បានជាខ្មែរច្រើនខ្សត់ខ្សោយជាងគេ នគរយើងទៀតក៏ទន់ទាបជាងគេដែរ, ឧទាហរណ៍កង ១ថ្ងៃ ៗ ត្រូវតែយើងធ្វើការឲ្យបានច្រើនម៉ោង ហើយយើងត្រូវនៅទំនេរនោះក៏ឲ្យតិចម៉ោងចុះមកដែរ ត្រូវឲ្យលៃយ៉ាងដូច្នេះពីឥឡូវនេះស្មើដរាបទៅ ទើបជាតិយើងនឹងដំណើរទៅកាន់សេចក្ដីចំរើនបាន ។

២ – បើជាអ្នកធ្វើការរាជការ ត្រូវប្រព្រឹត្តតាមម៉ោងតាមពេលតាមនាទីដែលច្បាប់កំណត់ ; បើចូលដល់កន្លែងធ្វើការកាលណាហើយ គួរគោរពគោរតខ្ជាបច្បាប់ ត្រូវយកចិត្តទុកដាក់កងកិច្ចការរបស់ខ្លួន កុំបណ្ដែតបណ្ដោយបង្អង់ទុកឲ្យយឺតយូរទៅថ្ងៃក្រោយ ។

៣ – បើជាកុមារអ្នកសិក្សារៀនសូត្រ ត្រូវខំយកចិត្តទុកដាក់កងការរៀនឲ្យទាន់ពេលទាន់វេលា ត្រូវប្រតិបត្តិតាមច្បាប់គ្រូដែលដាក់កំរិតឲ្យ ទើបដំណើរទៅរកសេចក្ដីចំរើនបាន ។

បើជាភិក្ខុបសម្បទាជិតវិញ ក៏ត្រូវមាននាទីដូចគ្នា គឺ បើចូលបួសជាភិក្ខុសាមណេរ ត្រូវខំសិក្សាសូត្ររៀនស្វាធ្យាយធម៌ ធ្វើកិច្ចវត្ត បោសច្រាស តាមនាទីដែលលោកបង្គាប់ ។ បើជាចៅអធិការវិញ ក៏ត្រូវដឹងលក្ខណៈគ្រប់យ៉ាង គឺ ឲ្យស្គាល់សារគារវត្ត ព្រំប្រទល់នៃផែនទីវត្ត នឹងទិសម្រាប់វត្ត ឲ្យដឹងភិក្ខុសាមណេរកងវត្ត មានសេចក្ដីទុក្ខសុខដូចម្ដេច

ខ្ទះ ហើយខំយកចិត្តទុកដាក់ថែទាំបោសប្រាសព្រះវិហារកុដិសាលាៗណា ដែលបាក់បែក ទ្រុឌទ្រោមត្រូវជួសជុលឡើងជាថ្មី ៗ ត្រូវដាស់តឿន ភិក្ខុសាមណេរក្នុងវត្ត ឲ្យខំស្វាធ្យាយន៍សូត្ររៀន គន្ថធុរៈ វិបស្សនាធុរៈ និងព្រះវិន័យ នឹងឲ្យខំថែទាំទីលំនៅ បោសប្រាសក្នុងព្រះវិហារ កុដិ តាមកិច្ចដែលត្រូវធ្វើឲ្យស្អាតបាតល្អ ៗ នេះហើយជានាទីរបស់មនុស្ស ដែលត្រូវធ្វើឲ្យចំរើនលោកបំពេញៈលាភឲ្យបានដំណើរជឿនទៅមុខ ឲ្យ ទាន់ពេលទាន់សម័យ ៗ

ម្យ៉ាងទៀត បើប្រសិនណាជាអ្នកធ្វើស្រែ ចំការ តែមានសេចក្ដីខ្ជិល ច្រអូស ហើយមិនរវល់នឹងការងារដែលខ្លួនធ្វើ ដូចធ្វើស្រែគ្មានភ្លឺ ទឹក ហូរអស់រលីង នាំដីជាតិក្នុងស្រែចេញទៅ តើស្រូវធ្វើម្ដេចនឹងបានចំរើន ; ការដែលខ្ជិលច្រអូសឡែឡមិនប្រព្រឹត្តការងារឲ្យហ្មត់ចត់ ក្នុងរបររកស៊ី របស់ខ្លួនសោះ ដូចដីស្រែយើងនឹងជាំជាតិអ្វីទៅក៏សុទ្ធតែដុះបានផល តិចច្រើនពុំខាន តែមកពីមានសេចក្ដីខ្ជិលមិនធ្វើ បើធ្វើបានផលបន្តិចបន្តួច ហើយឈប់បង្អង់, មានការដើរលេងអបាយមុខ ត្រឡប់មកផ្ទះវិញដេកផ្ងំ ក្ដុយ អង្គុយសំឡឹងជង្រុកស្រូវសំរាប់នឹងកាយកល់ ដូរចំណីក្នុងអំរែក ចិន ដាក់ប់លុះអស់រលោណាក៏ដើរសូមទានគេ ដេកអង្គុយតាមផ្លូវថ្កល់ ទទូរមេឃ ស្ងៀកអាកាស មើលទៅគួរឲ្យខ្មាសជល់ជាតិដទៃជាទីបំផុត ៗ

បំណែកអ្នកពជការគួរគិតថា បើយើងមិនខំប្រឹងធ្វើការឲ្យទាន់ពេល វេលា ក្នុង ១ ថ្ងៃឲ្យខ្ទះ ១ ម៉ោងជាដរាប បើ ១០០ នាក់ ១ ថ្ងៃខាត ១០០

ម៉េង តើខាតប្រាក់ប៉ុន្មានទៅ ដែលទទេគ្មានធ្វើការ?, ម្ល៉ោះហើយការដែលសល់នៅបេះតែច្រើនឡើង ៗ

កុមារអ្នកសិក្សាសូត្ររៀន បើចៅឯងមិនខំប្រឹងស្វាធ្យាយន៍ទន្ទេញតាមរបៀបគ្រូដាក់ឲ្យទេ គ្រាន់តែទៅអង្គុយក្នុងសាលា, ចេញពីសាលាមក ដើរលេងអហ្វាយមុខ ហើយទន្ទឹងចាំមើលតែថ្ងៃអាទិត្យនឹងថ្ងៃព្រហស្បតិ៍ ដូច្នេះតើដំរេះវិជ្ជានឹងកើតដូចម្ដេចបាន? ឱចៅអើយ! ស្រុកយើងនឹងចំរើនឡើងបានមកពីដំរេះវិជ្ជា ដែលអ្នកឧស្សាហ៍រៀនសូត្រនេះឯង, បើចៅមិនខំប្រឹងហើយ ចៅឲ្យអ្នកណាខំប្រឹងជួស, ឱចៅ! លោកតាមានសេចក្ដីសង្ឃឹមលើចៅឯងណាស់ ដូចសុភាសិតបុរាណថា "ឱចៅកំព្រា ពន្លកស្ពនក្ស សំឡាញ់ឪពុក បណ្ដុលសាច់ត្រួយ តែមួយជាមុខផលកេរ្ដិ៍គាលស្រុក ស្រែភ្លឺសច់ផៅ" ៗ ពាក្យនេះ ចូរចៅគិតមើលឲ្យវែងឆ្ងាយទៅចុះ ៗ ចំណែកបព្វជិត បើមិនប្រព្រឹត្តតាមកិច្ចដែលត្រូវប្រព្រឹត្តទេ តើដែលបួសមកនឹងមានប្រយោជន៍អ្វី? មនុស្សយើងត្រូវមានមុខនាទីកាន់កាប់ គឺជាបព្វជិត ត្រូវរក្សាព្រះពុទ្ធសាសនាឲ្យបានចំរើនរុងរឿងឡើងទៅ, បើជាគ្រហស្ថ ត្រូវធ្វើការងារឲ្យចំរើនផែនដី ដើម្បីនឹងជួយទំនុកបំរុងជាតិ សាសនា មហាក្សត្រ ៗ នេះជានាទីរបស់មនុស្ស ដែលមិនបង្អៀតលោក ៗ មានមនុស្ស ១ បំពួកទៀត គ្មាននាទីធ្វើអ្វីទេ នៅអាស្រ័យនឹងអ្នកដទៃខ្លះ នៅអាស្រ័យក្នុងវត្តលោកសង្ឃខ្លះ តែគ្មាន

របររកស៊ី ។ បើប្រសិនជានៅវត្ត តែមានរបរការងារ ទោះធ្វើការរាជការក្តី ធ្វើជំនួញក្តី នៅបណ្តោះអាសន្នទម្រាំនឹងរកផ្លូវបាន នេះក៏មិនជាការអ្វីទេ ។ តែមនុស្សដែលទំនេរគ្មានការធ្វើសោះ ខ្លះអួតអាងថាខ្លួនចាស់ឈប់រកស៊ី អាស្រ័យនៅវត្តរក្សាសីល ខ្លះថាមិនទាន់ដល់ពេលវេលានឹងរកស៊ី ។ មនុស្សបំពូកនេះអង្គុយសំឡឹង ចាំអាស្រ័យដោយសារលោកសង្ឃ មានប្រេនសឹងតែគ្រប់វត្ត គ្រប់កន្លែង ហេតុនេះគួរជាតិខ្មែរយើងលះគំនិតថោកទាបនេះចោលចេញ ទើបស្រុកមិនសាបសូន្យ ។ សេចក្តីដូចសំដែងមកខាងលើនេះ សូមឲ្យយុវជនយុវតីរួមជាតិទាំងឡាយខំដុសខាត់កំចាត់ចេញ នូវសេចក្តីខ្ជិលច្រអូសទាំងប៉ុន្មានឲ្យខាត់ឆ្ងាយពីសន្តានចិត្តឲ្យអស់ ហើយខំតាំងខ្លួនរៀបខ្លួនប្រកបការងារតាមថ្នាក់តាមជាន់ឲ្យទាន់សម័យឡើង ដើម្បីនឹងបានជាកម្លាំងជួយស្ទួយជាតិសាសនានឹងមហាក្សត្ររបស់យើងឲ្យរុងរឿងតទៅ ។

ទុក្ខប្បត្តា ប និទ្ទុក្ខា ភយប្បត្តា ប និព្ភយា
សោកប្បត្តា ប និស្សោកា ហោន្តុ សព្វេបិ បាណិនោ

សព្វសត្វទាំងឡាយ ដែលដល់នូវសេចក្តីទុក្ខ សូមឲ្យជាអ្នកបាត់ទុក្ខទៅ ! ដែលដល់នូវភ័យ សូមឲ្យជាអ្នកបាត់ភ័យទៅ ! ដែលដល់នូវសោក ក៏សូមឲ្យជាអ្នកបាត់សោកទៅ ! ។

ដោយតេជះព្រះរតនត្រ័យ សូមឲ្យប្រជាជនទាំងឡាយ ដល់នូវការលូតលាស់ចំរើនទីងសន្តិភាពកុំបីឲ្យឃ្លាត ក្លាយទៅជាប្រការអ្វីឡើយ ។

ខាងចុងបំផុតធម៌ទេសនានេះ យើងសូមប្រកាសដល់ទេវតាទាំងឡាយថា: ក្នុងឆ្នាំនេះ ជានាទីរបស់ធុង្សទេវបុត្តជាអ្នករក្សាលោកឲ្យបានសេចក្តីសុខ សេចក្តីចំរើន ហេតុនេះ យើងសូមរំលឹកដល់ធុង្សទេវបុត្តម្តងទៀត តាំងអំពីពេលព្រឹកស្អែកនេះទៅសូមឲ្យរាំងតាំងស្មារតីកុំឲ្យធ្វេសប្រហែស ១ មីនុតសោះ ចូរខំរក្សាលោកយើងនេះឲ្យបានចំរើនបានសេចក្តីសប្បាយ, បើមានបច្ចាមិត្រមកអំពីទីណាក្តី ឬកើតឡើងក្នុងមណ្ឌលក្រុងកម្ពុជានេះក្តី ក៏សូមទេវតាជួយកំចាត់បំបាត់ចិត្តអាក្រក់ល្អក់កកររបស់បច្ចាមិត្រទាំងឡាយនោះ ឲ្យក្លាយទៅជាមិត្តភាពវិញ ហើយសូមជួយទំនុកបំរុងជាតិសាសនានឹងព្រះមហាក្សត្រ ឲ្យបានចំរើនរុងរឿងតទៅខាងមុខ ។

អាត្មាភាពសំដែងមកក្នុង ទិដ្ឋធម្មិកធម៌ គឺធម៌ជាគ្រឿងនាំមកនូវប្រយោជន៍ដល់លោក ក៏ល្មមសមគួរដោយពេលវេលាត្រានេះឯង ឯវំ ។

បប់

---

# ប្រស្នាពិធីបុណ្យខ្មោច

## ឃុនបណ្ណានុរ័ក្ស ប៊ូ-ប៉ូ នៅពុទ្ធសាសនបណ្ឌិត្យ

ស្រង់អំពីក្បួនចាស់បុរាណមករៀបរៀង

---

១ – ស. ការណ៍ដែលគេយកប្រាក់ដាក់ក្នុងមាត់ខ្មោច ដើម្បីប្រយោជន៍អ្វី?

១ – ឆ. មានរឿងគេដំណាលតៗ គ្នាមកអំពីបុរាណថា មានបុរសប្ដីប្រពន្ធ (ពីរនាក់) នៅជាមួយគ្នាតាំងពីក្មេងដល់ចាស់ មានមាសដាប់ទឹងខ្លួនប្រមាណ ១ បាទ ។ ប្ដីផ្ដាំប្រពន្ធៗ ផ្ដាំប្ដីថា: បើអ្នកណាស្លាប់មុន ឲ្យយកមាសនេះដាក់មាត់ ។ បំណោរតមកមិនយូរប៉ុន្មាន ប្ដីស្លាប់មុនទៅ ប្រពន្ធក៏យកមាសនោះដាក់មាត់ប្ដីហើយយកខ្មោចប្ដីទៅដុត ភ្លើងឆេះមាសនោះខាតអស់នៅសល់តែត្រឹម ៣ ស្លឹង ។ សម័យមួយព្រះមហាក្សត្រមានលោភចិត្តគ្របសង្កត់ឲ្យរៃយកមាសក្នុងមួយផ្ទះ ១ បាទ ។ យាយជាប្រពន្ធរបស់ខ្មោចតានោះ ទៅរើសយកមាសដែលបង់មាត់ប្ដីក្នុងគំនរឆ្អឹងនោះបានតែ ៣ ស្លឹង យកទៅថ្វាយព្រះមហាក្សត្រ ហើយក្រាបទូលថា "ពីដើមមាសនេះពេញ ១ បាទ ខ្ញុំបង់មាត់ឲ្យប្ដីៗ យកទៅមិនបាន, ភ្លើងឆេះអស់ខ្វះទៅនៅសល់តែប៉ុណ្ណេះ សូមព្រះអង្គជាទីពឹងទ្រង់ព្រះមេត្តាដល់សត្វទាល់ក្រចុះ" ។ ព្រះមហាក្សត្រទ្រង់ព្រះសណ្ដាប់ក៏កើតធម្មសង្វេគស្លុតព្រះទ័យ ទើបទ្រង់ប្រកាសលើកលែងមិនឲ្យរៃយកមាសអំពីបណ្ដារាស្ត្រ ។

អាស្រ័យហេតុនេះ អ្នកប្រាជ្ញពីបុរាណ ទើបយកមាសប្រាក់ដាក់ក្នុងមាត់ខ្មោចដើម្បីឲ្យពិចារណា ៗ ក្នុងប្រស្នានេះត្រូវពិចារណាថា សម្បត្តិទាំងអស់ យើងយកជាប់នឹងខ្លួនទៅបានខ្លះ តែក្នុងវេលានៅមានជីវិត, កាលបើស្លាប់ហើយ យកទៅមិនបានទេ; សូម្បីនៅរស់ក៏លំបាកនឹងយកសម្បត្តិទាំងអស់នោះ ជាប់ទៅជាមួយខ្លួនដែរ ព្រោះជួនកាលបណ្ដាលឲ្យកើតអន្តរាយដោយសត្រូវលួចប្លន់ ឥតបោកដណ្ដើមយកទៅក៏មាន, ចំណង់បើមនុស្សស្លាប់ហើយ ធ្វើម៉េចនឹងយកទៅបាន លោកប្រាប់ថាជាអនិច្ចំ ជារបស់មិនទៀងទាត់ស្ថិតស្ថេរ ជាសម្បត្តិសាធារណៈឥតអ្នកណាជាម្ចាស់ឡើយ ៗ យកប្រាក់ឬមាសបង់មាត់ខ្មោចសម្រាប់ឲ្យពិចារណានោះ ក៏មានជាប់រហូតមកដល់សព្វថ្ងៃនេះ ៗ

២ – ស. ដែលគេយកផ្កានឹងទៀនធូបដាក់ក្នុងដៃខ្មោចនោះតើប្រាថ្នាអ្វី?

២ – ឆ. កាលពីមុន មានភិក្ខុមួយរូបមិនប្រាកដឈ្មោះ ៗ ញោមប្រុសរបស់លោកធ្វើជាព្រានព្រៃ សម្លាប់សត្វច្រើនណាស់តាំងពីក្មេងដល់ចាស់ លុះវេលាជិតស្លាប់ក៏ភ្លឹកស្មារតីទៅឃើញតែសត្វផ្សេងៗដែលខ្លួនធ្លាប់សម្លាប់ដោយអកុសលចិត្ត ទើបស្រែកប្រាប់ឲ្យលោកកូនជួយ ៗ ភិក្ខុជាកូនដឹងថាញោមកម្មច្រើន បានជាភ្លឹកទៅឃើញតែសត្វដូច្នោះ ទើបចាត់មនុស្សឲ្យរកផ្កាទៀនធូបដាក់ក្នុងដៃញោមប្រុសរួចប្រាប់

ថា "ញោមបូរសំឡឹងមើលផ្កាទៀនធូបនេះជាគ្រឿងបូជាព្រះរតនត្រ័យ" ។ ញោមប្រុសនៃភិក្ខុនោះកើតសទ្ធាជ្រះថ្លាមានចិត្តជាកុសល បានធ្វើតាមពាក្យគូន លុះដល់ស្លាប់ហើយបានទៅកើតនៅនាស្ថានសួគ៌ ។ ព្រោះហេតុនេះ បានជាមនុស្សជាន់ក្រោយធ្វើតាមគ្នាមក ដោយប្រាថ្នានឹងឲ្យអ្នកជម្ងឺជិតស្លាប់សំពះបូជាគុណព្រះរតនត្រ័យយកជាទីពឹង ។ មានអ្នកស្រុកខ្លះនិយាយថា: ដើម្បីឲ្យមនុស្សឈឺជិតស្លាប់បូជាព្រះចូឡាមណីចេតិយដែលនៅក្នុងស្ថានតាវត្តិង្ស ។ ស្ទួរថាយ៉ាងនេះក៏កប់ចូលក្នុងកិច្ចបូជាព្រះរតនត្រ័យដែរ ។ រឿងនេះបានជាប់ជាទំនៀមរហូតមកដល់សព្វថ្ងៃនេះ ។

៣ - ស. គេទាញរនាប ៣ ចំរៀកពាយក្អមទឹក ៣ នោះ តើព្រោះហេតុអ្វី?

៣ - ឆ. រឿងនេះ អ្នកប្រាជ្ញពីបុរាណបានធ្វើឲ្យជាប្រស្នាធម៌ឲ្យមនុស្សជាន់ក្រោយគិតពិចារណា ។ គឺរនាប ៣ ចំរៀកនោះ បានដល់ជាតិការកើតអាស្រ័យដោយភព ៣ គឺកាមភព ១ រូបភព ១ អរូបភព ១ ។ ឯក្អមទឹក ៣ នោះ បានដល់វ័យទាំង ៣ គឺបឋមវ័យ ១ មជ្ឈិមវ័យ ១ បច្ឆិមវ័យ ១ ។ សត្វដែលកើតក្នុងភព ៣ ត្រូវតែបែកធ្លាយស្លាប់ទៅវិញក្នុងវ័យទាំង៣ វ័យណាមួយជាមិនខាន មិនបានរស់នៅរហូតតទៅទេ ។ ប៉ុន្តែរឿងនេះ មិនសូវមានគេធ្វើទេ ឃើញធ្វើតែវេលាសែនខ្មោច

ចេញពីផ្ទះទៅ គឺគេបោះក្អមទឹក ១ ទៅដីឲ្យបែក និងថូ ១ ដុំផង ។ សូម្បីធ្វើយ៉ាងនេះ ក៏ត្រូវតាមទំនៀមខាងលើនេះដែរ បានជាជាប់មានប្រពៃណីនេះតមក ។

៤ - ស. គេហាមមិនឲ្យសែងខ្មោចក្រោមធ្នឹមផ្ទះនោះតើ ព្រោះហេតុអ្វី?

៤ - ឆ. ព្រោះផ្ទះគេទាប ក្រែងអ្នកសែងខ្មោចទៅនោះទង្គិចក្បាលនឹងធ្នឹមផ្ទះគេ បានជាគេហាម ។

៥ - ស. គេហាមមិនឲ្យសែងខ្មោច ឬដឹកខ្មោចកាត់ស្រែចំការគេនោះតើ ព្រោះហេតុអ្វី?

៥ - ឆ. ព្រោះហេតុម្ចាស់ស្រែចំការនោះខ្លាចក្រែងអ្នកសែងខ្មោចដើរទៅជាន់ស្រូវឬដំណាំរបស់គេ បានជាគេហាមដូច្នោះ ។

៦ - ស. គេសែងខ្មោចប្រទក្សិណជើងថ្ករ ៣ ជុំនោះ តើដើម្បីប្រយោជន៍អ្វី?

៦ - ឆ. អ្នកប្រាជ្ញពីបុរាណធ្វើឲ្យឃើញជាប្រស្នាថា: បុថុជ្ជនគឺបុគ្គលដែលគ្រាស់ទៅដោយកិលេស រមែងកើតចាស់ឈឺស្លាប់វិលវល់នៅក្នុងវដ្តសង្សារ មិនរួចពីវដ្តសង្សារទៅបានឡើយ ។ ហេតុនោះបានជាលោកឲ្យប្រទក្សិណជើងថ្ករ ដើម្បីឲ្យយល់យ៉ាងនេះ ។

៧ - ស. គេយកផ្កាភ្ញីធូបទៀនទៅដាក់ឲ្យខ្មោចក្នុងពេលរៀបនឹងដុតនោះតើ ដោយហេតុដូចម្តេច?

៧– ឆ. តាមប្រវេណីពីបុរាណរបស់យើងប្រកាន់ថាជាការបុណ្យកុសលយ៉ាងច្រើន ។ លុះតមកដល់សម័យនេះសេចក្តីតាំងចិត្តដូច្នោះក៏ថយតិចទៅ វេលាទៅដុតខ្មោចយកផ្កាកំរៀនធូបទៅសូមខមាទោសនឹងខ្មោចក្រែងខ្លួនបានប្រមាថមើលងាយឬចំអកចំអន់លេងសើចដោយសំដី ។ មួយទៀត អ្នកខ្លះគេគាក់តែងផ្កាជាក្បាច់របនាផ្សេងៗ អស់ប្រាក់ជាច្រើន ដើម្បីឲ្យកើតកិត្តិយសដល់ខ្មោចនោះផង ដើម្បីតបគុណខ្មោចនោះផង ទាំងនេះចាត់ជាការបុណ្យកុសលបានដូចគ្នា ។

៨– ស. គេសូមខមាទោសនឹងខ្មោចបានដែរឬអ្វី?

៨– ឆ. បានក៏មាន មិនបានក៏មាន ។ ទោសស្រាលៗ ដូចយ៉ាងគប់ទះគ្នាលេងនឹងដៃ ឬ ក៏និយាយចំអកចំអន់គ្នាលេងនឹងមាត់ ដូច្នេះសូមខមាទោសបាន ។ ទោសធ្ងន់ៗ ដូចយ៉ាងកាប់សម្លាប់គេ លួចរបស់ទ្រព្យគេ លួចកូនប្រពន្ធគេ និយាយកុហកឬញុះញង់គេ ដូច្នេះសូមខមាទោសមិនបានទេ គឺថាទោសនោះមិនបាត់ឡើយ ។

៩– ស. កាលនឹងដុតខ្មោច ហេតុអ្វីបានជាគេហាមមិនឲ្យអុជភ្លើងតពីគ្នា?

៩– ឆ. រឿងនេះមិនមែនជាប្រស្នាកងធុរធម៌ទេ ហេតុតែអ្នកមានភ្លើងមុន ខ្ជិលកាន់ឈើចាំឲ្យអ្នកក្រោយអុជបន្តទៅទៀត ប៉ុនជាគេហាមដូច្នោះ ។ មួយទៀត ចាស់បុរាណគិតក្រែងថា កាលបើចេះ

តែអុជបន្តគ្នាច្រើនៗទៅ អ្នកកាន់ភ្លើងឲ្យគេអុជនោះទ្រាំនឹងកំដៅភ្លើងមិនបាន មុខជាបោះភ្លើងចោលទៅត្រូវគេរលាកសាច់ឬក៏ឆេះសំពត់អាវ ហេតុនេះបានជាគេហាមមិនឲ្យអុជភ្លើងបន្តពីគ្នា ។

១០ — ស. កាលនឹងដុតខ្មោច ហេតុអ្វីក៏ដាក់ឲ្យដេកផ្កាប់មុខរួចបានដុត គេមិនដុតផ្ងារ?

១០ — ឆ. បើឆ្លើយតាមផ្លូវធម៌ថា: ធម្មតាមនុស្សយើងកើតមកដោយអវិជ្ជា ស្លាប់ទៅវិញក៏ដោយអវិជ្ជា គឺសេចក្តីល្ងង់ខ្លៅមិនដឹងតាមពិតមកគ្របសង្កត់សន្តាន មិនដឹងប្រមាណដល់សង្ខារដូចជាបុគ្គលដែលដេកផ្កាប់មិនដឹងខ្លួនថានឹងមានភ័យអន្តរាយមកពីទិសខាងណា បានជាគេដុតខ្មោចផ្កាប់ដូច្នោះ ដើម្បីឲ្យកើតសង្វេគក្នុងធម៌ ។ បើឆ្លើយតាមផ្លូវលោកវិញថា: គេដុតផ្ងារមិនកើតទេ ព្រោះដល់ភ្លើងឆេះខ្មោចទៅសរសៃរួញឡើងទាញខ្មោចឲ្យក្រោកបះផ្កឹង, បើឲ្យផ្កាប់មុខហើយយកឥសដាក់សង្កត់ពីលើខ្នងឲ្យធ្ងន់ទៅ សរសៃទាញមិនរួច ហេតុនេះបានជាគេដុតខ្មោចតែផ្កាប់មុខ ។

១១ — ស. ដែលគេយកខ្សែបាសចងក ចងដៃ ចងជើងខ្មោចនោះ តើដើម្បីប្រយោជន៍អ្វី?

១១ — ឆ. ដើម្បីឲ្យឃើញជាប្រស្នាតាមផ្លូវធម៌ដូចមានបាលីថា: បុត្តា គីវេ "កូនជាអន្ទាក់ផ្ទាក់ក" ធនំ បាទេ "ទ្រព្យជាអន្ទាក់ផ្ទាក់

ជើង" ក៏ហៅ ហត្ថ "ប្រពន្ធជាអន្ទាក់ធ្លាក់ដៃ" ។ បើអ្នកណាផុតពីអន្ទាក់ទាំង ៣ នេះបាន អ្នកនោះទើបផុតចាកសង្សារវដ្ត ។ ន័យមួយទៀតថា គេចង់កុំឲ្យខ្មោចនោះលាដៃជើងប្រងេងប្រងាង ។

១២ – ស. កាលគេដុតខ្មោចសុះអស់ហើយ មុននឹងរើសឆ្អឹង ហេតុអ្វីក៏ចាំប្រមូលធ្យូងធ្វើជារូបមនុស្សប្រែចុះប្រែឡើង?

១២ – ឆ. ដែលគេធ្វើដូច្នោះហៅថា "ប្រែរូប" ដើម្បីនឹងឲ្យពិចារណាកម្មដ្ឋានតាមលំអានព្រះពុទ្ធដីកាថា ឲ្យភិក្ខុពិចារណាអសុភតាំងពីចុងជើងដល់ក្បាល តាំងពីក្បាលដល់ចុងជើង ។ ដែលគេធ្វើរូបឲ្យបែរក្បាលទៅទិសខាងលិចនោះ ដើម្បីនឹងឲ្យពិចារណាតាមអត្ថថា: អនិច្ចាវត សង្ខារា ។ល។ ដូច្នេះជាដើម ។ ដែលគេធ្វើរូបឲ្យបែរក្បាលទៅទិសខាងកើតនោះ ដើម្បីនឹងឲ្យពិចារណាតាមអត្ថថា អចិរំ វតយំ កាយោ ។ល។ ដូច្នេះជាដើម ដោយសេចក្តីកើតនឹងស្លាប់ជាគូគ្នា ។ ដែលគេធ្វើរូប ៣ ដងនោះ ដើម្បីនឹងឲ្យពិចារណាទៅតាមភពទាំង ៣ មានកាមភពជាដើម ។

១៣ – ស. កាលគេនឹងដុតខ្មោច ហេតុអ្វីបានជាគេដាក់ក្បាលខ្មោចឲ្យបែរទៅទិសខាងលិច?

១៣ – ឆ. រឿងនេះប្រកាន់តៗគ្នាមកតាំងពីកាលព្រះឥសូរកោរដុកព្រះពិឃណេស ជាបុត្រ ដូចមានដំណាលតាមសាសនាព្រាហ្មណ៍

ថា: ព្រះឥសូរវៀបគោរដុកឲ្យព្រះពិឃណោសមិនបានប្រាប់ព្រះអគ្គិរឲ្យជាបផង ព្រះអគ្គិរខ្ញាល់ក៏បណ្ដាលឲ្យកាំបិតគោរទៅ កាត់យកក្បាលព្រះពិឃណោសបោះចោលទៅកង់សមុទ្របាត់ទៅ ។ ព្រះឥសូរក៏ប្រើព្រះពិស្ណុកម្ម ឲ្យទៅកាត់យកក្បាលមនុស្សនឹងសត្វតិរច្ឆានដែលដេកបែរក្បាលទៅទិសខាងលិច ។ ព្រះពិស្ណុកម្មទៅរកមើលឃើញដំរីតីរដេកបែរក្បាលទៅទិសខាងលិច ក៏កាត់ក្បាលដំរីនោះយកមកតថ្វាយព្រះពិឃណោស បានជាព្រះពិឃណោសមានក្បាលជាដំរី ។ ព្រោះហេតុនេះ បានជាមនុស្សទាំងឡាយប្រកាន់តៗ គ្នាមកថា ដេកបែរក្បាលទៅទិសខាងលិចកើតអពមង្គល គេប្រកាន់ថាមនុស្សរស់គួរដេកបែរក្បាលទៅទិសខាងកើត មនុស្សស្លាប់ឲ្យដេកបែរក្បាលទៅទិសខាងលិច ក៏ជាប់ជាទំនៀមតៗ គ្នាមក ។

១៤ - ស. កាលដុតខ្មោចរួចហើយត្រឡប់មកផ្ទះវិញ ហេតុអ្វីក៏គេឲ្យង្ងូតទឹក ?

១៤ - ឆ. គេឲ្យង្ងូតទឹកតែពួកក្មួកជាអ្នកដុតខ្មោចប៉ុណ្ណោះទេ ព្រោះខ្លួនគេប្រឡាក់ប្រឡូស បំណែកអ្នកឯទៀតបើង្ងូតទឹកក៏ជាការល្អ ព្រោះការជម្រះញើសក្អែលរបស់ខ្លួនឲ្យស្អាត ជាហេតុឲ្យពន់កាយល្អផង បានសេចក្ដីសុខផង ។

១៥ - ស. ខាងខ្មែតត្រូវដុតគូ ខាងនោបត្រូវដុតសេស ខ្មោចដុតមនុស្សៗ ដុតខ្មោច នោះដូចម្ដេច?

១៥ — ឆ. មានរឿងតំណាលថា: ដើមដំបូងកូនប្រុសសេដ្ឋីក្នុងទីក្រុង ជាសំឡាញ់នឹងកូនប្រុសសេដ្ឋីក្រៅក្រុង សំឡាញ់ទាំងពីរនាក់នោះស្រឡាញ់ស្រីតែម្នាក់រួមគ្នា ស្រីនោះបានប្តេជ្ញាថា "បើអ្នកព្រមស្លាប់ជាមួយគ្នាទើបខ្ញុំព្រមព្រៀងតាមប្រពៃណី" ។ សំឡាញ់ទាំងពីរក៏ទទួលប្តេជ្ញា ។ លុះយូរមកស្រីនោះស្លាប់ ញាតិសន្តានក៏នាំសពទៅដុត ត្រូវលើថ្ងៃ ១៥ កើត ដុតរួចនាំគ្នាវិលមកផ្ទះវិញ ។ កូនសេដ្ឋីក្នុងក្រុងគ្រាន់តែដឹងហេតុនោះភ្លាម ក៏រត់ទៅលោតចូលក្នុងគំនរ[illegible]សដែលភ្លើងនៅមិនទាន់រលត់ ។ លុះដល់ព្រឹកឡើងថ្ងៃ១រោច មនុស្សទាំងឡាយនាំគ្នាចេញទៅមើល ក៏ឃើញមនុស្សស្លាប់ក្នុងគំនរភ្លើង ទើបនាំគ្នាសន្និដ្ឋានថា ដុតខ្មោចថ្ងៃសីលមិនល្អទេ បែរជាខ្មោចដុតមនុស្សវិញ ។ រួចក៏បបួលគ្នាដុតខ្មោចនោះឲ្យឆេះសុះអស់ទៅ ។ ហេតុនេះហើយបានជានាំគ្នាប្រារព្ធថា ខាងខ្នើតត្រូវដុតសព ១ ខាងរនោចត្រូវដុតសព ២ ។ ពាក្យអ្នកស្រុកថា ខាងខ្នើតដុតគូ ខាងរនោចដុតសេស ជាប់រហូតមកដល់សព្វថ្ងៃនេះ ។

តមកមិនយូរប៉ុន្មាន កូនសេដ្ឋីក្រៅក្រុងដឹងហេតុនោះហើយ ក៏ប្រញាប់មករើសឆ្អឹងខ្មោចទាំងពីរ ដាក់ក្នុងក្អមបងព្យរទឹកទៅរកព្រះឫសីៗ ក៏ឧបជាស្រីជាប្រុសឡើង ។ ឫសីសួរនាងនោះថា "នាងឯងចូលចិត្តនៅជាមួយនឹងប្រុសណា" ។ នាងនោះឆ្លើយថា "ខ្ញុំចូលចិត្តនៅជាមួយនឹងប្រុសដែលស្លាប់ផងគ្នា" ។ ឫសីក៏ប្រសិទ្ធផ្ដុំឲ្យប្រុស

នោះទៅ ។ ប្រុសដែលយកឆ្អឹងចងកទៅឥតបានអ្វីសោះ ទើបមានពាក្យទំនៀមថា "សាច់មិនបានស៊ី ស្បែកមិនបានទ្រាប់អង្គុយ ឆ្អឹងព្យួរក" ។

១៦ – ស. គេធ្វើជណ្តើរ ៣ កាំ សំគាល់សេចក្តីថាអ្វី?

១៦ – ឆ. លោកថា បានដល់ភព ៣ គឺកាមភព ១ រូបភព ១ អរូបភព ១ ។ ដ្បិតមនុស្សប្រុថុជ្ជនត្រវិលវល់ឡើងចុះនៅក្នុងភព ៣ នេះ មិនទាន់ឈានទៅឲ្យផុតបានទេ ។

១៧ – ស. ហេតុអ្វីបានជាគេស្មៀកសំពត់ឲ្យខ្មោចយកថ្នក់ទៅខាងក្រោយខ្លួនវិញ?

១៧ – ឆ. លោកតែថា សត្វកើតដោយទិដ្ឋិ ស្លាប់ដោយទិដ្ឋិ មានអវិជ្ជាបិទមុខបិទក្រោយ នឹងមានតណ្ហាចាក់ស្រែះគ្នាទៅទៀត ។

១៨ – ស. ដែលគេធ្វើអម្រែក ៣ មានអាហារចំណីនោះ តើគេយកទៅឲ្យអ្នកណា?

១៨ – ឆ. កត្តាហារក្នុងអម្រែក ៣ នោះ ហៅតាមមគធភាសាថា មតកកត្ត គឺកត្តរបស់អ្នកស្លាប់ ជាអាហារដែលញាតិមិត្រ នឹងបញ្ជូនទៅឲ្យត្រឹងកន្ទេងដែលនៅវិលវល់ក្នុងភពបី ។

១៩ – ស. ហេតុអ្វីបានជាគេឲ្យកូនប្រុសបួសមុខភ្លើង?

១៩ – ឆ. ហេតុតែជីដូនជីតាមាតាបិតាមានគុណ កូនចៅមានចិត្តកតញ្ញូកតវេទី ហើយបួសដើម្បីឧទ្ទិសផលផ្លសជូនទៅលោកអ្នកមានគុណដែលស្លាប់ទៅនោះ ។

២០ – ស. ដែលគេបំអាសទឹកខ្មោចតើ ដើម្បីប្រយោជន៍អ្វី? ហេតុអ្វីបានជាអ្នកម្ចាស់ខ្មោចហៅញាតិមិត្រឲ្យមកបំអាសទឹកខ្មោចនោះផង?

២០ – ឆ. រឿងបំអាសទឹកខ្មោចនោះ គេប្រកាន់តាមសេចក្ដីយល់ឃើញប្លែកៗ គ្នា ។ ជាតិក្លិង្គប្រកាន់ថាផ្ចូតទឹកលាបមេ្យឲ្យខ្មោចស្អាតបាតហើយ កាលទៅកើតជាតិមុខទៀតនឹងមានរូបរាងស្អាតល្អ ។ ពួកព្រាហ្មណ៍ប្រកាន់ថា ផ្ចូតទឹកលាងបាបឲ្យ ដ្បិតព្រាហ្មណ៍ជឿថា ទឹកក្នុងស្ទឹងគង្គាជាទីលាងបាប មនុស្សឈឺជិតស្លាប់ឬស្លាប់ទៅហើយ ក៏នាំគ្នាទៅដងទឹកស្ទឹងគង្គាមកលាងបាបឲ្យអ្នកនោះដែរ ។ ឯពួកខ្មែរយើងជាអ្នកកាន់ព្រះពុទ្ធសាសនាលើកយកសេចក្ដីកតញ្ញូជាធំ បានជានាំគ្នាមកផ្ចូតទឹកឲ្យខ្មោច ដោយសេចក្ដីត្រេកអរថាលោកជាអ្នកមានគុណ ព្រមទាំងមកសូមខមាទោសកុំឲ្យមានកម្មពៀរនឹងគ្នាផង ។

២១ – ស. ហេតុអ្វីបានជាគេនិមន្តលោកសូត្រព្រះធម៌តែ៤អង្គប៉ុណ្ណោះ? បើនិមន្តលោកឲ្យច្រើនលើសពី ៤ អង្គឡើងទៅបានឬទេ?

២១ – ឆ. ហេតុតែអ្នកម្ចាស់ខ្មោចប្រាថ្នាថា ព្រឹកឡើងនឹងបានថ្វាយសង្ឃទានគ្រប់ជាអង្គសង្ឃ ដើម្បីនឹងបានឧទ្ទិសបំណែកកុសលនោះទៅឲ្យអ្នកស្លាប់ ។ បើនិមន្តលោកឲ្យច្រើនលើសពី ៤ អង្គឡើងទៅឬតិចជាងនេះក៏បានឥតទាស់ខុសអ្វីទេ បើនៅជាសង្ឃទាន ក៏បានដូចគ្នា ។

២២ – ស. ការដែលគេនិមន្តលោកមកសូត្រព្រះធម៌នោះតើ គឺសូត្រឲ្យមនុស្សរស់ស្ដាប់ ឬឲ្យមនុស្សស្លាប់ស្ដាប់?

២២ – ឆ. សូត្រឲ្យមនុស្សរស់ស្ដាប់ ដើម្បីឲ្យពិចារណាក្នុងមរណានុស្សតិថា កើតមកជារូបកាយរមែងមានសេចក្ដីស្លាប់ជាទីបំផុត, ឯមនុស្សស្លាប់ស្ដាប់មិនបានទេ ។

២៣ – ស. បើស្ដាប់មិនបានដូច្នោះ ហេតុអ្វីបានជាគេគោះក្ដារមឈូសប្រាប់ខ្មោចឲ្យទទួលសីល?

២៣ – ឆ. រឿងនេះជាទិដ្ឋិរបស់ព្រាហ្មណ៍ខាងក្រៅព្រះពុទ្ធសាសនា ប្រកាន់ថាសត្វស្លាប់ហើយ ព្រលឹងឬអាត្ម័នរបស់សត្វនោះ មិនបានរលត់ទេ ប៉ុន្តែដែលគេធ្វើដូច្នោះ ខ្ញុំក៏មិនយល់មិនដឹងសេចក្ដីបំណងយ៉ាងណារបស់គេដែរ ។

២៤ – ស. ក្នុងវេលាមានបុណ្យខ្មោច គេស្លៀកដណ្ដប់សំពត់សខ្លះ ខ្មៅខ្លះ ឬមានសំពត់ខ្មៅបន្ដិចសៀតនៅដៃអាវឬត្រង់ទ្រូងខ្លះ គេធ្វើយ៉ាងនោះតើ ព្រោះហេតុអ្វី?

២៤ – ឆ. ដែលគេស្លៀកពាក់សនោះ ប្រហែលជាខ្មែរយើងយកតម្រាប់តាមចិន ព្រោះចិនគេប្រើរបស់សជាគ្រឿងកាន់ទុក្ខក្នុងវេលាញាតិមិត្តស្លាប់ ឬមួយទៅជួយបុណ្យសពគេឯទៀតក៏ប្រើសដែរ ។ ឯការស្លៀកពាក់សនេះជាតិខ្មែរយើងមានប្រើនតែអ្នកកាន់សីល ។ ចំណែកការស្លៀកពាក់ខ្មៅនោះ ប្រហែលជាយកតម្រាប់តាមពួកប្រទេសដទៃ ដែលគេប្រកាន់ថា មនុស្សយើងកាលធ្វើបុណ្យខ្មោចរបស់ខ្លួនក្ដី ទៅ

ជួយគេក្តី គួរប្រើរបស់ខ្មៅ ព្រោះពណ៌ខ្មៅជាពណ៌ស្លាប់ប្រែប្រួលទៅទៀតមិនកើត ។ បំណោរតមក លោកអ្នកខ្លះយល់ឃើញថាការស្លៀកពាក់ខ្មៅសុទ្ធ មិនជាការសំខាន់ណាស់ទេ គួរតែឲ្យមានរបស់ខ្មៅបន្តិចជាប់នឹងខ្លួនក៏បានហើយ ទើបនាំគ្នាធ្វើសំពត់ពណ៌ខ្មៅបន្តិចជាប់នឹងខ្លួនរហូតមកដល់សព្វថ្ងៃនេះ ប៉ុន្តែអ្នកដែលស្លៀកពាក់សសុទ្ធឬខ្មៅសុទ្ធក៏មានគង់តែសំដែងខ្លួនថាជាអ្នកកាន់ទុក្ខក្នុងបុណ្យសពដូចគ្នា ។

២៥ – ស. ហេតុអ្វីបានជាគេបើកក្តារមឈូស បើមិនបើកបានឬទេ?

២៥ – ឆ. ដែលគេបើកនោះ ព្រោះពីដើមកាលបើមានមនុស្សស្លាប់ហើយ គេយកដើមឈើមួយកំណាត់មកលុងជាប្រហោងឲ្យស្អាតល្អរួចលើកខ្មោចដាក់ចូលទៅ ។ កាលបើទុកខ្មោចយូរថ្ងៃ ខ្មោចនោះហើមប៉ោងធំឡើងទាល់តែតឹងចង្អៀតក្តារមឈូស ខាងក្រោយមកបានជាគេបើកក្តារមឈូសឲ្យធំទូលាយជាមុនសិន រួចទើបយកខ្មោចដាក់ចូលទៅដើម្បីការពារកុំឲ្យក្តារមឈូសបែកធ្លាយ ។ ដល់មកឥឡូវនេះគេបើកទាំងធំទាំងតូច ។ ប៉ុន្តែគួរបើកតែក្តារមឈូសតូច ឯក្តារធំស្រាប់ហើយមិនគួរបើកទេ ។

ប្រស្នាពិធីបុណ្យខ្មោចចប់ប៉ុណ្ណោះ

# រឿងស្តេចត្រី

## លោកផេង-ជឿរ សាស្ត្រាចារ្យ នៅសាលាគរុវិជ្ជា ភ្នំពេញ

ប្រែពីសៀវភៅ «កុង អេ ឡេហ្សង់ ឌុយប៉េអ៊ី រូម៉ាំងត្រាឌី ប៉ាអេ អាដាប្តេ ប៉ា ប.នរ៉ឹន»

(តពីរឿងមនុស្សថ្មក)

---

កន្លងកាលដ៏កន្លងទៅហើយ មានបុរសម្នាក់រកស៊ីដោយការនេសាទត្រី, គាត់មានកូនប្រុសមួយដែលគាត់ចង់ឲ្យធ្វើជាអ្នកនេសាទដូចគាត់ទៀត ។ ថ្ងៃមួយ គាត់ទៅបង់សំណាញ់ជាមួយនឹងកូន បានត្រីមួយយ៉ាងល្អ ស្រកាភ្លឺដូចពេជ្រ ។ គាត់យកត្រីនោះដាក់ទុកនៅលើមាត់ត្រពាំង ឲ្យកូននៅចាំរក្សា ហើយត្រឡប់ទៅបង់សំណាញ់ទៀត ។

កាលដែលបុរសចេញផុតទៅ ត្រីក៏និយាយត្អូញត្អែរ ទឹកភ្នែកហូរ រហាមថា: បពិត្រកុមារ? ខ្ញុំជាស្តេចត្រី សូមអ្នកមេត្តាបោះខ្ញុំទៅក្នុងទឹកវិញ ខ្ញុំនឹងដឹងគុណអ្នកទៅថ្ងៃក្រោយជាមិនខាន ។

ត្រីនោះចេះនិយាយត្អូញសូម្បីតែដុំថ្មក៏ទន់តាមដែរ, កុមារអាណិតត្រីក្រៃពេកដោយពាក្យសំដីដូច្នោះ ទើបចាប់បោះទៅក្នុងទឹកវិញទៅ ។ មច្ឆាត្រេកអរអនេកអនន្ត ហែលចុះហែលឡើង មុជងើបៗ វាត់កន្ទុយបែកទឹកខ្ចាយ រួចមុជទៅបាត់ ។

ប៉ែហុលមួយស្របក់ធំ អ្នកនេសាទត្រឡប់មកវិញ ខឹងរអ៊ូទាំ ដើរនាយដើរអាយ ព្រោះបង់សំណាញ់ឥតបានត្រីសោះ សូម្បីតែបង្គា

មួយក៏គ្មាន សួរកូនថា នែអាណុប! ម៉េចត្រីយើង ប្រហែលរួចមួយពេលបានឬទេ? ។

— ពុក! ខ្ញុំបោះវាទៅក្នុងទឹកវិញទៅហើយ វានិយាយនឹងខ្ញុំ ហើយអង្វរខ្ញុំ សុំឲ្យលែងវា ដ្បិតវាជាស្ដេចត្រី ។

អ្នកនេសាទ ព្រួយព្រោះ ខឹងកូន ស្ទុះដាក់កូន កួសៗ, ទោះបីកូនស្រែកអូយយ៉ាយ អូយយ៉ូយ ដូចម្ដេចក៏ដោយ ក៏គាត់មិនឈប់ត្បក ។ គាត់ត្បករហូតទាល់តែរួយដៃ ឈឺម្រាមដៃទើបឈប់ ។ បុរសឪពុកនឹងកូនត្រឡប់ទៅផ្ទះវិញដៃទទេ, ល្ងាចនោះគ្មានអ្វីធ្វើម្ហូបសោះ អត់ទាំងបាយទៀតផង ។

ព្រឹកឡើង បុរសឪពុកទាត់ធាក់កូនទៀត ដោយគ្មានរឿងហេតុអ្វី ។ លុះបានសេចក្ដីទុក្ខខ្លាំងពេក ថ្ងៃមួយ កុមារក៏សត្រាំនៅមិនបាន ក៏លួចរត់ចេញពីផ្ទះអាត្មាទៅ ។ កុមារនោះដើរទៅៗ ដល់ទីក្រុងមួយ ។ គ្រាន់តែចូលទៅដល់ភ្លាម មានអាតៀម្នាក់ដែលឈរផ្អែកនឹងកំពែងគេហស្ថានមួយ ដើរមកឲ្យពរ ទាក់សួស្ដី ដល់ចៅកំសត់ៗ ដោយខ្លួនអនាថា លុះឃើញហេតុដ៏ល្អដូច្នោះ ក៏ត្រេកអរពេក ហើយសុំចងមិត្តភាពជាមួយនឹងអាតៀ ។ រួចជនទាំងពីរ ធ្វើកតិកាសញ្ញាទៅវិញទៅមកថា យើងកុំបែកគ្នា ហើយចាប់តាំងពីពេលនេះទៅ បើយើងបានវត្ថុអ្វី គង់បែកគ្នាបរិភោគ ។

ចែកគ្នា...? មែនហើយ ប៉ុន្តែចែកអ្វី? បើគ្មានមួយសេនបោះ ។ ខណៈនោះពៅកំសត់ទាំងពីរ សម្រេចគ្នាទឹងទៅរកស៊ីឈ្នួលគេ ទើបនាំគ្នាទៅនៅស៊ីឈ្នួលទីងផ្ទះចៅកែម្នាក់ ខាងក្រោយដែលបានសម្រេចថ្លៃឈ្នួលហើយ ។

ថ្ងៃមួយ អាតៀកាលដែលបានធ្វើការរួចសព្វគ្រប់ហើយ ទៅឈរលេងនៅក្បែរមាត់ទ្វារកំពែង ហើយបានឃើញមនុស្សម្នាក់ជិះសេះ មានសេះដទៃទៀតប្រាំទឹងខ្ញុំម្នាក់រត់តាមក្រោយ ។ ព្រឹកឡើងម៉ោងដដែល មនុស្សជិះសេះទៅជាមួយទឹងខ្ញុំរូបដទៃវិញ ។ ព្រឹកស្អែកឡើងទៀត គេឃើញគាត់ទៅជាមួយទឹងខ្ញុំផ្សេងពីថ្ងៃទីពីរ, ហើយដំណើរនេះតែងមានដូច្នេះតទៅ រៀងរាល់ថ្ងៃ ។ អាតៀបេះតែនឹកពិភាល់ក្នុងចិត្តថា: ចុះបាវមុនៗ តើគេយកទៅធ្វើអ្វីអេះ? ។ អាតៀដោះស្រាយប្រស្នានេះមិនរួចសោះ ។ លុះទីបំផុត ក៏ដាច់ចិត្តទៅតាមមនុស្សជិះសេះ ដើម្បីលួចយកការណ៍ឲ្យបានដឹងជាក់ ។

អាតៀទៅឯផ្សារ ហើយឈររេកឈប់ចាំមើល ។ មិនយូរប៉ុន្មាន លេចមនុស្សជិះសេះមកដល់ គឺជាគហបតីម្នាក់ ។ គាត់ជួលមនុស្សម្នាក់ ហើយឲ្យឡើងជិះសេះបរតាមពីក្រោយ ។ ចំណែកអាតៀបេះតែលបរត់តាមក្រោយជនខាងលើនេះ ។ មុនដំបូង គេត្រូវតាមវាលស្មៅប្រកបដោយផ្ការុក្ខជាតិផ្សេងៗ ។ រួចគេចូលក្នុងព្រៃស្មសាន

គេចរយ៉ាងយូរ ទើបទៅឈប់នៅក្បែរឈើមួយដើម ។ គេចុះពីសេះ ។ គហបតីទាញយកខ្សែពីការុង ចងភ្ជាប់នឹងដែកគោលមួយ ដែលបោះទុកនឹងដើមឈើនោះ បោះកន្ទុយខ្សែរំលងកាត់មែកខាងលើ ហើយបង្គាប់ឲ្យអ្នកបំរើតោងកន្ទុយខ្សែនោះឡើងទៅ ។ អ្នកបំរើឡើងដល់ចុងឈើ ហើយបានឃើញកញ្ជើមួយដ៏ធំ ពេញដោយត្បូងពេជ្រមានដម្លៃ ។ អ្នកនេះស្រែកពីលើដើមពោធិមកថា: អា! លោកម្ចាស់! សុទ្ធតែត្បូងច្រើនណាស់ ។

គហបតីនិយាយថា: ដាក់ចុះមក! កុំស្រែកហ៊ោកញ្ជ្រៀវនៅលើហ្នឹងខ្លាំងពេក! ។ អ្នកបំរើដាក់កញ្ជើមក, ខាងក្រោយដែលដាក់ត្បូងកងការុង គហបតីហុចកញ្ជើតាមខ្សែទៅឲ្យទុកត្រង់កន្លែងដដែលវិញ ។ អ្នកស៊ីឈ្នួលធ្វើតាមសេចក្តីបង្គាប់របស់គហបតី, ប៉ុន្តែពេលដែលត្រូវចុះមកវិញរកខ្សែប្រតោងគ្មាន ។ ក៏ស្រែកប្រាប់ថា: លោកម្ចាស់! បោះខ្សែមកឲ្យខ្ញុំផង ដើម្បីនឹងចុះ, ខ្ញុំលោតចុះទៅមិនបានទេ មុខជាត្រូវបាក់ជើងឬបែកក្បាលស្លាប់ជាមិនខាន ។

កុដុម្ពិកគិតតែពីរៀបចំការុងចងមាត់ លើកដាក់លើខ្នងសេះ មិនរវល់ឆ្លើយ ។ អ្នកបំរើស្រែកប្រាប់ទៀតថា នែលោកម្ចាស់! ឮឬទេ? លេងសើចប៉ុណ្ណឹងបានហើយ ។ អ្នកស៊ីឈ្នួលប្រឹងស្រែកប្រាប់ជាច្រើនម៉ាត់ ប៉ុន្តែគហបតីធ្វើដូចជាមិនដឹងមិនឮ លោតផ្លោះឡើង

លើខ្នងសេះ ហើយបរសេះបំផាយទៅបាត់ ៗ បុរសកំសត់ស្រែកឡើងថែមទៀតថាៈ នែលោកម្ចាស់! លោកម្ចាស់! ឈប់ ឈប់! សូមលោកវិលមកជួយដាក់ខ្ញុំចុះសិន មិនត្រូវយកខ្ញុំបាទមកទុកចោលក្នុងទីរហោឋានដូច្នេះទេ ៗ គហបតីប្រឹងតែបំផាយសេះគ្មានស្តាប់អ្វីទាំងអស់ ៗ

ជីងថាខ្លួនទៅតែឯងហើយៗ មិនគឺជាការលេងសើចពិត បុរសអកុសល តាំងស្រែកទ្រហោយំក្តែងៗ ក្នុងកណ្តាលដងព្រៃស្ងាត់ជ្រងំ ៗ ចំណែកអាតៀមិនបង្ហាញខ្លួនឲ្យឃើញ ព្រោះត្រូវការចង់ដឹងរឿងតទៅទៀត ៗ វេលានោះ កាលដែលបុរសកំសត់កំពុងយំហោចសក់គក់ទ្រូង មាននាគមួយមាត់ធំសម្បើមគួរស្ញែង ងើបចេញពីរូងក្បែរគល់ឈើលូនឡើងសិទ្ធិមៗ រហូតដល់ចុងឈើ ហាមាត់ចង្រ្កង ធ្មេញប៉ុនប៉ែលហើយលេបបុរសនោះទាំងមូលតែម្តង ៗ ខាងក្រោយដែលវាបានស៊ីមនុស្សហើយនាគនោះហាមាត់ជាថ្មីម្តងទៀត ខ្ជាក់សុទ្ធតែត្បូងពេជ្រគ្រប់ពណ៌ មានក្រហម បៃតង ទទឹមជាដើម ទាល់តែកញ្ជើពេញជាថ្មីម្តងទៀត រួចវាលូនចុះមកវិញ ត្រឡប់ចូលក្នុងរូងបាត់ទៅ ៗ

នៅឱកាសនោះ ការភ័យតក់ស្លុតនឹងសេចក្តីអាណិតមេត្តា ធ្វើឲ្យអាតៀឈរនៅតែមួយកន្លែងស្រឡាំងកាំងមិនហ៊ានកំរើកអាត្មា ហើយវារត់យ៉ាងឆាប់ត្រឡប់ទៅកាន់ទីក្រុងវិញ ៗ លុះព្រឹកស្អែក កាលណាលោកគហបតីទៅឯផ្សារជាមួយនឹងសេះរបស់លោក តើលោកអ្នកមាន

រាល់គ្នា នឹកស្មានថា នរណានឹងសុំស៊ីឈ្នួលលោកគហបតី ដើម្បីជាជំនួយដល់លោកក្នុងព្រៃ? គឺតួអាតឿនេះឯង ដែលវាបានដឹងរឿងរ៉ាវសម្ងាត់សព្វគ្រប់ ហើយវាមានគំនិតអ្វីមួយ ក្នុងខួរក្បាលវា ។

កាលបើនិយាយថ្លៃឈ្នួលត្រូវគ្នាហើយ អាតឿឡើងជិះសេះតាមលោកគហបតីទៅ ។ វាបរច្នងកាត់ទីក្រុងជាមួយលោកសេដ្ឋី ឆ្លងវាលស្មៅ កាត់តម្រង់ចូលព្រៃ ហើយបានដល់ដើមឈើដែលយើងនិយាយពីលើកមុន ។ លោកគហបតីបោះខ្សែសំតោកក្ដាម អាតឿឡើងក្តួតយកទាំងកញ្ជើដាក់ចុះមក តាមសេចក្ដីឲ្យការណ៍នៃលោកគហបតី ។

លោកសេដ្ឋីចាក់ត្បូងពេជ្រដាក់ក្នុងការុង ហើយមានបំណងចង់ឲ្យអាតឿឡើងយកកញ្ជើទៅទុកត្រង់កន្លែងដដែលវិញ ។ តែអាតឿប្រកែកថា: ' ខ្ញុំវិលមុខណាស់ ឈប់ឡើងទៀតហើយ '' ។

លោកគហបតីសួរទាំងខឹងថា: ចុះបើវឹង, តើកញ្ជើឲ្យអញធ្វើដូចម្ដេចទៅ អាតឿឆ្លើយឡើងថា: ចំណែកកញ្ជើមានពិបាកអី លោកឡើងខ្លួនលោកយកទៅដាក់ទៅ តែប៉ុណ្ណឹងក៏ស្រេចហើយ ។

លោកសេដ្ឋីផ្ញឹងថា: "បើប្រសិនជាលោកឡើងដោយខ្លួនឯង នោះត្រូវតែត្រឡប់មកវិញ លោកមិនមែនឆ្កួតនៅទំលើចុងឈើឲ្យនាគវាលេបឡើយ, ចុះបើត្រឡប់ចុះមកវិញ គ្មាននរណាម្នាក់នៅលើទីនោះៗ សមខានបានត្បូងពេជ្រទៅថ្ងៃក្រោយ '' ។

លោកសេដ្ឋីនិយាយទៅកាន់អាតឿទៀតថា: ចូរឯងឡើងឲ្យអញមួយក្អេតទៅ ឯងនឹងត្រូវបានពេជ្រមួយគ្រាប់ជាមិនខាន ។

អាតឿឆ្លើយថា ទេ! ។

- ចូរឯងឡើងទៅ អញមិនថាកុហកឯងទេ ។

អាតឿដេកនទៀលនៅដី ហើយស្រែកប្រាប់លោកសេដ្ឋីថា: ឱលោកអើយ! ដីរលេកឡាប់ចក្រហើយ ។

លុះនិយាយទៅមកៗ មួយសន្ទុះមិនសម្រេចការ លោកសេដ្ឋីសុខចិត្តព្រមយកកញ្ឆើឡើងទៅវុក ដោយខ្លួនឯង ។ គឺត្រង់ហ្នឹងហើយដែលអាតឿវត្រូវការ ។ គ្រាន់តែលោកសេដ្ឋីឡើងដល់ចុងឈើភ្លាម អាតឿបាត់វិលមុខ ស្ទុះមកចាប់កន្ទុយខ្សែកន្ទ្រាក់ចុះ ទុកឲ្យលោកសេដ្ឋីនៅជាប់ទើរលើចុងឈើ ។

លោកសេដ្ឋីស្រែកថា: ទុកខ្សែឲ្យអញ អាឯងធ្វើអីចឹង? ទុកខ្សែឲ្យអញដើម្បីអញចុះ! ។ អាតឿលោតជិះលើខ្នងសេះហើយប្រាប់ថា: សូមលោកអញ្ជើញនៅលើចុងឈើហ្នឹងចុះ ស្រួលហើយ ។

- អាតឿ! អាតឿ! ពេជ្រទាំងការុង ឯងយកចុះ អាណិតតែយកខ្សែមកពាក់ឲ្យអញ ដើម្បីឲ្យអញចុះ ។

អាតឿមិនរវល់ស្តាប់ ។ កាលណាវជិះលើកែបប្រង់ប្រៀបនឹងបរថយចេញ វបែរទៅរកសេដ្ឋីម្តងទៀត ហើយស្រែកប្រាប់ថា: "ម្នាល

សំឡាញ់! ចូរឯងនៅទំលើចុងឈើហ្នឹងហើយ ចូរចាំសួស្តីមានដល់ឯង" រួចវាគោះសេះបំផាយត្រឡប់វិលមកទីក្រុងវិញ ។

លោកគហបតី លោតកញ្ជ្រោលអន្ទះអន្ទែងបោចសក់ឥតអំពើ នៅលើចុងព្រឹក្សា ព្រោះគ្មានផ្លូវអីសោះដើម្បីនឹងដោះខ្លួន ឥឡូវគិតនឹងលោតចុះ គង់តែក្រសាប់កំណើតគ្មាន ។ ម្ល៉ោះហើយគាត់គិតតែពីយំទ្លួញខ្សឹកខ្សួលរហូតទាល់តែនាគុត្សសូរ វាលូនឡើងមកហើយលេបុទាំងរស់... ។ គឺជាសេចក្តីស្លាប់ទាំងវេទនារបស់គាត់ ។

ឥឡូវអាតឿចង់ទៅឯផ្ទះលោកគហបតី ប៉ុន្តែធ្វើដូចម្តេច? បើវាមិនស្គាល់ផ្ទះលោកសោះ ។ អាតឿបណ្តោយឲ្យសេះដើរតាមចិត្តវា ៗ ដើរនាំទៅត្រង់ទីលំនៅលោកសេដ្ឋី ។ បុរសកន្ទុញឃើញទ្វារបិទជិត លុះរកទៅរកមកវាប្រទះកូនសោមួយក្នុងការុង រួចវាចាក់សោចូលក្នុងផ្ទះ ៗ អាតឿស្រឡាំងកាំងស្រពាំងភ្នែក ដោយឃើញសុទ្ធតែគំនរត្បូងពេជ្រភ្លឺចិញ្ចាច កន្លែងនេះគឺជាឃ្លាំងដែលសេដ្ឋីសម្រាប់យកត្បូងទាំងប៉ុន្មានមកលាក់ទុកដោយការសម្ងាត់ ។ អាតឿរៀបចំភ្លាមៗ យកការុងត្បូងចាក់ចេញហើយ រត់ទៅរកសំឡាញ់របស់វា ។ អាតឿមកដល់ ឃើញកូនប្រុសនេសាទមានមុខស្លុតក្រៀម ។ កុមារនេះកាលបើបានយល់សម្លាញ់ ក៏មានមុខរីករាយដូចបានឃើញព្រះជាម្ចាស់ ។ វាសួរហើយសួរទៀត ទូវអាតឿថា: ចុះឯងទៅណា? ឯងទៅធ្វើអ្វី? ឯងទៅណា

អីយូរម្ល៉េះ? ។ អាតៀឆ្លើយថា: អញនឹងនិយាយប្រាប់រឿងដល់សម្លាញ់ឥឡូវហ្នឹង ប៉ុន្តែចូរសំឡាញ់ទៅបើកប្រាក់ថ្លៃឈ្នួលយកមកហើយទៅជាមួយនឹងអញ ។ កូនអ្នកនេសាទ ទៅរកនាយចៅហ្វាយមួយរំពេច ហើយប្រាប់ថា វាឈប់ធ្វើការហើយ សុំបើកយកប្រាក់ថ្លៃឈ្នួល ។ ចៅកែជាចៅហ្វាយនាយសួរថា ចុះឯងវាថី មានរឿងអ្វី? តើរឿងអ្វី ធ្វើឯងឲ្យចង់ទៅណា យ៉ាងដូច្នេះគ្មានដឹងមុខបាត? ។ កូនអ្នកនេសាទឆ្លើយថា: ត្រូវឲ្យថ្លៃឈ្នួលខ្ញុំមក ! ត្រូវឲ្យថ្លៃឈ្នួលខ្ញុំមក ខ្ញុំលាទៅហើយ ។

ចៅកែនោះគិតថា: អានេះឆ្កួតទេតើ, បើដូច្នេះត្រូវចេញថ្លៃឈ្នួលដល់វាឲ្យឆាប់ ហើយបណ្តេញវាចេញ មុនពេលដែលវាបង្ករឿងអាក្រក់អ្វីមួយដល់អញ... ។ នេះនែ អានាង (ចៅហ្វាយហុចថ្លៃឈ្នួលឲ្យ) ចូរឯងទៅចុះ សូមឲ្យព្រះជាម្ចាស់ជួយតាមរក្សាឯងឲ្យបានសេចក្តីសុខ ។

កូនអ្នកនេសាទចេញពីផ្ទះនោះ ហើយទៅជាមួយអាតៀវសំដៅឃ្លាំងខ្មោចលោកសេដ្ឋី ។ វាឈរនឹងថ្កល់តែមួយកន្លែងវេលាដែលបានឃើញគំនរទ្រព្យទាំងប៉ុន្មានដែលសម្លាញ់វាប្រាប់ថា ជារបស់វាទាំងពីរនាក់ ។

– អាហ៎ សំឡាញ់! ឯងកុំនិយាយលេងដូច្នេះ ។

– ចឹងមែន អញមិនថាលេងទេ ។

– អីទ្រព្យទាំងអស់ហ្នឹងជារបស់ផងយើង? ។

– មែន ទាំងអស់ហ្នឹង ។

កូនអ្នកនេសាទ   វេលាដែលអាតៀនិយាយរឿងប្រាប់សព្វគ្រប់ ក៏តបថា : អីដូច្នេះសំឡាញ់ ! ឯងមិនគ្រាន់បើណាស់ហើយ ? ។

ក្នុងឱកាសនោះ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ក្នុងព្រះនគរនោះ បានបាត់ឲ្យគេប៉ាវគងប្រាប់អស់អាណាប្រជារាស្ត្រថា បើឈ្មោះណាបានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងព្រះរាជធីតាព្រះអង្គហើយៗ អាចបានអាស្រ័យតំណេកនៅជាមួយគ្នា ក្នុងបន្ទប់របស់នាងអស់មួយរាត្រី រហូតដល់ព្រះអរុណរះឡើង នោះព្រះអង្គនឹងទុកអ្នកនោះជាព្រះសុណិសារបស់ទ្រង់ ដ្បិតព្រះរាជធីតានោះ បានរៀបមង្គលការជាមួយនឹងបុរសអស់ចំនួនកៅសិបប្រាំបួនហើយៗ លុះព្រឹកឡើង គេរកស្វាមីមិនឃើញៗ តែគំនរឆ្អឹង ម្ល៉ោះហើយព្រះរាជាមានព្រះហឫទ័យសង្ស័យពេក មិនទ្រង់ជ្រាបថានរណាជាគូបច្ចាមិត្រសោះ ។

អាតៀបានដឹងដំណឹងដូច្នោះ យល់ដើងការណ៍ ក៏ទៅកាន់ព្រះរាជវាំងភ្លាម ហើយក្រាបបង្គំទូលព្រះចៅថា សំឡាញ់របស់រាបង់ផ្សងរកសនា ល្បងធ្វើជាព្រះសុណិសានៃព្រះរាជាលមើល ។ ព្រះរាជាទ្រង់ទទួលដោយមានព្រះហឫទ័យរីករាយ ហើយមានព្រះរាជឱង្ការថា ចូរឲ្យវាមកយ៉ាងឆាប់ បើវារស់រួចបានមួយយប់ នោះកូនស្រីរបស់យើងនឹងត្រូវបានទៅវាធ្វើជាប្រពន្ធគេទៅ ។

អាតៀត្រឡប់ទៅរកកូនអ្នកនេសាទជាសំឡាញ់ ដោយរួសរាន់ឥតបង្អង់ វិលនាំយកមកក្នុងព្រះរាជវាំង ហើយវេលារាត្រីកាលណាសំឡាញ់

របស់ព្រះនាងទាំងពីរនោះ ព្រះរាជធីតានាំគ្នាចូលក្នុងបន្ទប់ ក៏ទៅតាមក្នុងទីនោះដែរ រួចដេកនឹងដីក្បែរគ្រែ ។

ពេលកណ្ដាលអធ្រាត្រ អាតឿក្រោកឡើង លើកបីសំឡាញ់ដែលកំពុងដេកលក់នៅជាមួយនឹងព្រះអង្គម្ចាស់ក្សត្រីយកទៅដាក់លើគ្រែមួយដទៃ ទាញដាវចេញមកហើយអង្គុយចាំមើល ។ ក្នុងមួយស្របក់ស្រាប់មានពស់មួយយ៉ាងធំ គួរស្ញប់ស្ញែង វាចេញពីក្នុងរូបព្រះរាជធីតាមក ; អាតឿព្រលែងមួយដាវដាច់ក ។ ខណៈនោះ វាស្ទុះទៅដាស់សំឡាញ់វា ហើយនិយាយថា: នែសំឡាញ់ ! ឯងចាំពាក្យខសន្យាដែលយើងនិយាយគ្នាលើកមុនថា: បើយើងបានវត្ថុអ្វីត្រូវយើងបែងចែកគ្នាពាក់កណ្ដាលម្នាក់ ឬទេ? ។ កូនអ្នកទេសាទឆ្លើយថា: ពិតមែនហើយសំឡាញ់ ។

គ្រានោះអាតឿដាវនៅដៃ ស្ទុះសំដៅព្រះអង្គម្ចាស់ក្សត្រី ដោយបញ្ចេញវោហាថា នឹងពុះព្រះរាជធីតាជាពីរចំណែក ដើម្បីនឹងយកភាគរបស់ខ្លួន ។ ព្រះនាងភ័យតក់ស្លុតរន្ធត់មហិមាទៅជាក្អួត ហើយមានស៊ុតមួយជ្រុះធ្លាក់ចេញពីព្រះឱស្ឋមក ។ អាតឿធ្វើជាស្ទុះទៅម្ដងទៀត បំរុងនឹងកាប់ពុះមែនទែន ។ ព្រះរាជធីតាក្អួតស៊ុតពីរចេញមកទៀត ។

អាតឿនិយាយប្រាប់សំឡាញ់ថា: ឥឡូវ ចូរឯងត្រឡប់យកប្រពន្ធរបស់ឯងទៅវិញចុះ ហើយចូរនៅជាសុខតរៀងទៅ, ពស់ដែលអញ

បានសំឡាប់ហើយអម្បាញ់មិញនេះ បានលាក់ស៊ុតបីនៅក្នុងព្រះឧស្ធនៃព្រះនាង, ស៊ុតទាំងនេះនឹងញាស់ទៅជាពស់ទៀត ប៉ុន្តែឥឡូវនេះវាធ្លាក់ចេញមកអស់ហើយ ។

អាតៀនោះមិនគឺអ្នកណាដទៃឡើយ គឺជាត្រីដែលកូនអ្នកនេសាទបានបោះទៅក្នុងទឹកវិញនោះឯង, ស្តេចត្រីនោះកាន់ពាក្យសត្យមកធ្វើឱ្យកុមារកំសត់មានសម្បត្តិ និង បានជាកូនប្រសាស្តេចផែនដី ។

អាតៀបានអធិប្បាយប្រាប់អំពីខ្លួនជាអ្វីសត្វគ្រប់ដល់កូនអ្នកនេសាទហើយប្រាប់ថា: ‹ ឥឡូវនេះ អញសុំលាសំឡាញ់ឯងហើយ ចូរសំឡាញ់បរិភោគជាសុខសប្បាន្ត ទាំងភរិយា ទាំងទ្រព្យសម្បត្តិទាំងឡាយនោះចុះ» រួចក៏អន្តរធានបាត់ពីទីនោះទៅមួយរំពេច ។

លុះព្រះអរុណរះឡើង កាលណាព្រះរាជាទ្រង់ជ្រាបថា ជនទាំងពីរនាក់ (ស្វាមីភរិយា) នៅគង់វង្សដដែល ឥតមានវិបត្តិអ្វីសោះ នោះព្រះអង្គមានព្រះរាជហឫទ័យសោមនស្សជាអនេកអនន្តរកទីបំផុតគ្មាន ។ គេធ្វើបុណ្យជាអធិកអធិក មានល្បែង មានរាំ និងល្បែងផ្សេងៗ សព្វគ្រប់អស់ប្រាំពីរយប់ប្រាំពីរថ្ងៃ ជាកិត្តិយសដល់គូស្រករថ្មី ។

ចប់

ការបណ្ដុះជំស្ស័យ

## ព្រះមហាឧត្តមវិជ្ជា ផលញ្ញាណោ ប៉ុង-ប៉ម

*អាចារ្យសាលាបាលីរង វត្តបទុមវតី ក្រុងភ្នំពេញ រៀបរៀង*

ឃុនបណ្ណាគុរ័ក្ស ប៊ូ-ប៉ូ នៅពុទ្ធសាសនបណ្ឌិត្យ អ្នកពិនិត្យកែ

(តមក)

---

៤.— វាចាមានប្រយោជន៍ *គឺសំដីដែលអំណោយប្រយោជន៍ដល់ខ្លួននឹងអ្នកដទៃ មិនមែនជាសំដីនិយាយលេងប៉ប៉េះប៉ប៉ោះប៉ប៉ាចប៉ប៉ោច ឥតផលឥតប្រយោជន៍ទេ ។ នៅសំដីនិយាយ មានហេតុមានផល ដែលវិញ្ញូជនចោទប្រកាន់ ប្រកាន់មិនបាន នឹងជាពាក្យនិយាយសមគួរដល់រឿងដែលពិត សមគួរដល់ភូមិធម៌របស់ខ្លួន សមគួរដល់កាលទេសៈនឹងបុគ្គល អាចបំភ្លឺមនុស្សដែលល្ងង់ឲ្យជាមនុស្សឈ្លាសវៃ ជប់មនុស្សវង្វេងឲ្យជាមនុស្សខុសលំទោន នឹងថែបុថុជ្ជនឲ្យជាព្រះអរិយៈបាន,* ធម្មវាទិតា *ជាសំដីនិយាយប្រាប់តែធម៌,* វិនយវាទិតា *ជាសំដីនិយាយប្រាប់តែវិន័យ,* និធានវតី *ជាសំដីមានគោលចារឹក,* សាបទេសា *ជាសំដីមានសំអាងជាក់លាក់,* កាលវាទិតា *ជាសំដីត្រូវកាល,* ភូតវាទិតា *ជាសំដីពិត,* អត្ថវាទិតា *ជាសំដីមានទឹកដម,* បរិយន្តវតី *ជាសំដីមានលក្ខណៈតាមច្បាប់ប្រពៃណី,* អត្ថសញ្ហិតា *ជាសំដីមានប្រយោជន៍ ។ បើនិយាយឲ្យកើត*

ប្រយោជន៍ ក៏កើតប្រយោជន៍. បើនិយាយឲ្យខូចប្រយោជន៍ ក៏ខូចប្រយោជន៍ ៗ ហេតុនេះ មុននឹងនិយាយសូមលោក-អ្នកគិតឲ្យហើយសិនសឹមនិយាយ ៗ ព្រោះការនិយាយមិនគិត តែងនាំឲ្យខូចប្រយោជន៍នឹងកើតអន្តរាយ ៗ គិតហើយទើបនិយាយ រមែងឲ្យកើតប្រយោជន៍យ៉ាងល្អក្រៃលែង ៗ ចូរប្រើពាក្យសំដីដែលនាំឲ្យកើតប្រយោជន៍ដោយទំនងដែលដឹងដើមដឹងចុង ដឹងក្បាលដឹងកន្ទុយ គឺឲ្យស្គាល់ពាក្យសំដីដែលល្អឲ្យចេះជ្រើសរើសរកពាក្យនិយាយឲ្យសមគួរនឹងពាក្យសំដីដែលនាំឲ្យកើតផលល្អឡើងទាំងខាងគេទាំងខាងយើង ៗ បើលោក-អ្នកនិយាយមិនឲ្យខូចប្រយោជន៍ខ្លួននឹងប្រយោជន៍អ្នកដទៃយ៉ាងនេះ ទើបចាត់ថា លោក-អ្នកមានសំដីល្អ ៗ បើប្រើវាចាដែលនាំឲ្យកើតប្រយោជន៍តែខាងខ្លួន ប៉ុន្តែប្រយោជន៍ខាងគេវិនាសនោះ មិនចាត់ថា មានសំដីល្អឡើយ ៗ ព្រោះថាបើការចំរើនមានផ្លូវម្ខាងហើយ ការវិនាសក៏មានផ្លូវម្ខាងដែរ ៗ

អ្នកដែលនិយាយនាំឲ្យកើតប្រយោជន៍ ព្រះពុទ្ធជាម្ចាស់ទ្រង់ហៅថា បុប្ផភាណី គឺជាមនុស្សមាត់ក្រអូប ដូចពូជឈើដែលមានក្លិនក្រអូបអាចបន្ទន់ចិត្តឲ្យរីករាយស្រស់ស្រាយសប្បាយបាន. ទាំងទ្រង់ត្រាស់ថា មធុភាណី ជាអ្នកមានវាចាផ្អែមធ្វើឲ្យអ្នកស្តាប់ក្រេបផឹកមិនចេះអស់ចំណង់ ដូចទឹកឃ្មុំយ៉ាងខាប់ក្នុងគិម្ហរដូវ ៗ មនុស្សបែបនេះចាត់ថាជាអ្នកមានជីវិតរស់នៅ ដើម្បីសួស្តីដល់មហាជន ព្រោះតែ

ព្យាយាមប្រើតែពាក្យដែលជាប្រយោជន៍ ចៀសវាងរឿងដែលឥតប្រយោជន៍ ប្រាជ្ញាបង្អួលបង្ហាញហេតុផលឲ្យច្បាស់ប្រាកដ ទាំងក្នុងផ្លូវលោក ទាំងក្នុងផ្លូវធម៌ ដោយសេចក្តីមេត្តាករុណា ដើម្បីឲ្យអ្នកស្តាប់មានសេចក្តីដឹង សេចក្តីចូលចិត្តបានត្រឹមត្រូវ ហើយកើតឧស្សាហ៍ក្នុងការប្រព្រឹត្តខ្លួនឲ្យផុតចាកសេចក្តីវិនាស និងនាំខ្លួនទៅកាន់សេចក្តីចំរើនសួស្តីបានផង រហូតដល់ព្យាយាមពន្យល់រឿងជាន់ខ្ពស់ គឺណែនាំឲ្យស្គាល់ឲ្យឃើញទុក្ខរបស់លោកតាមសភាពពិត ឲ្យដឹងឲ្យឃើញថា អ្វីជាអណ្តូងកើតនៃទុក្ខ ឲ្យដឹងឲ្យឃើញការរលត់ទុក្ខ និងឲ្យដឹងឲ្យឃើញវិធីផ្លូវដែលនាំទៅកាន់ការរលត់ទុក្ខ ឈ្មោះថាជាអ្នកមានពាក្យទ្រទ្រង់ទុកនូវឧត្តមគតិដែលអ្នកស្តាប់ទាំងឡាយគួរអនុលោមតាម ។

បើអស់លោក អ្នកចង់ឲ្យសំដីរបស់ខ្លួនមានខ្លឹមសារ ដើម្បីឲ្យសម្រេចប្រយោជន៍ដល់ខ្លួននិងអ្នកស្តាប់ ចូរចេះដំកល់ពាក្យឲ្យតាំងនៅក្នុងមណ្ឌលនៃប្រយោជន៍ និងខំថែទាំសំដីរបស់ខ្លួនឲ្យជារបស់មានដំឡៃយ៉ាងថ្លៃបំផុត ដោយការចរចាឲ្យល្មមប្រមាណនិយាយឲ្យត្រូវកាលវេលា និយាយរឿងដែលមានពិត និយាយពាក្យដែលមានទឹកដម និយាយពាក្យប្រកបដោយធម៌វិន័យ និយាយពាក្យមានគោលចារឹកតឹកតាង និងនិយាយពាក្យមានលក្ខណៈតាមច្បាប់ប្រវេណី ។ ព្រោះសំដីបែបនេះកាលបើនិយាយហើយ ក៏ឲ្យសម្រេចប្រយោជន៍របស់ខ្លួននិងរបស់អ្នក

ដទៃ ៗ ហេតុនេះ ត្រូវកុំនិយាយពាក្យដែលនាំឲ្យខូចប្រយោជន៍ទាំងពីរចំណែក កុំបណ្ដោយឲ្យមាត់និយាយសំដីសាបរលាបដោយការពោលឡេះឡោះ ឬនិយាយពាក្យអំនួតឡើយ ចូរនិយាយតែពាក្យដែលនាំឲ្យកើតសេចក្ដីពេះដឹង សេចក្ដីប្រព្រឹត្តល្អដល់មនុស្សដទៃ ៗ

សូមកុំភ្លេចថា : សំឡេងដែលយើងនិយាយគ្នាដោយរឿងដ៏ល្អលម្អញាំងគុណប្រយោជន៍ឲ្យកើតឡើងដល់មិត្តភក្តិនោះ ពីរោះក្រៃលែងជាងដូរ្យតន្ត្រីទៅទៀត ៗ ព្រោះសំឡេងដូរ្យតន្ត្រីទាំងឡាយ ដែលនិយមថាពីរោះនោះ កើតអំពីមនុស្សប្រតិស្ឋឡើង មិន មនកើតឯងទេ ហើយសូរគឹកកងនៃដូរ្យតន្ត្រីនោះទៀត ពិរោះ តែមួយភ្លេតក៏សូន្យទៅ ឯសំឡេងនៃពាក្យសំដីដែលនិយាយឬដឹកនាំគ្នាដោយរឿងដ៏ល្អវិញ ពីរោះរងំនៅក្នុងត្រចៀកមិនចេះបាត់ ៗ ដូច្នេះត្រូវមានសតិសម្បជញ្ញៈ កុំភ្លេចពិចារណាឡើយ ៗ ព្រោះមនុស្សដែលមិនពិចារណា តែងយកចិត្តមកទុកនៅតែត្រង់អណ្ដាត ៗ ឯមនុស្សដែលមានការពិចារណាវិញ ទើបយកអណ្ដាតទៅទុកត្រង់បេះដូង ៗ

បិត្តសភាព — វត្ថុសំខាន់បំផុតក្នុងការធ្វើនិងការនិយាយរបស់យើង គឺចិត្ត ៗ អាកប្បកិរិយានឹងវាចាដែលយើងសំដែងចេញមក រមែងជាផលនៃចិត្តដែលគិត ៗ សម្បកិច្ចការ ឬ សព្វវត្ថុ រូប ពណ៌ដែលយើងកសាងឡើងទាំងអស់ ក៏ជាផលកើតមកអំពីចិត្តគិតទាំងអស់ ៗ ហេតុ

ការណ៍ដែលបណ្តាលឲ្យការធ្វើការនិយាយរបស់យើងសម្រេចជាផលល្អឬអាក្រក់នោះ មិនមានអ្វីក្រៅអំពីចិត្តដែលគិតត្រូវឬខុសឡើយ ។ មើលចុះ! ប្រាក់បើមិនមានផ្សងចិត្តជាអ្នករចនាទេ ក៏នៅជាដុំដដែល ។ ដំណែងឋានន្តរៈ បើចិត្តអស់ចំណង់ហើយ ងារស័ក្តិ មេដៃយ៍ ដែលនៅត្រង់ទ្រូងអាវរបស់លោកនោះ ក៏ប៉ុនគ្នានឹងកំណាត់សំពត់ទេ ។ ក្នុងការងារគ្រប់ផ្នែក បើមិនគិតទុកជាមុនរួចចាំធ្វើ រួចចាំនិយាយទេ ក៏មុខជានាំពួកគណៈទៅកាន់សេចក្តីវិនាសពុំខាន ។ ដូច្នេះ កិច្ចការគ្រប់ជំពូកទាំងគតិលោកទាំងគតិធម៌ ទើបរួមនៅត្រង់ចិត្ត ។ បើចិត្តយើងល្អរមែងមានគុណជាអនេក ។ ចិត្តល្អ ឬ អារម្មណ៍ល្អនេះឯង ហៅថាចិត្តសុភាព ។ ចិត្តសុភាពនេះ មានលក្ខណៈ ៥ ប្រការ គឺ:

១ — ចិត្តស្ងប់ស្ងៀម — ចិត្តដែលស្ងប់ស្ងៀម ជាឫសគល់នៃសេចក្តីស្ងប់គ្រប់យ៉ាង ។ កាយវាចាដែលស្ងប់នោះ រមែងជាពន្លកឬជាមែកធាងមែកសាខាចេញមកពីចិត្តដែលស្ងប់ ។ បើយើងមានចិត្តស្ងប់ហើយ សូម្បីកាយវាចាក៏ស្ងប់តាម ព្រោះចិត្តជាអ្នកនាំមុខ ចិត្តជានាយចៅហ្វាយ ចិត្តជាអ្នកត្រិះរិះពិចារណា ។ អ្នកមានចិត្តស្ងប់តែងជាមនុស្សមានអារម្មណ៍ល្អ សំដែងការយល់ចិត្តយល់ថ្លើមគ្នា សំដែងខ្លួនជាមិត្តរបស់មនុស្សដទៃ ឲ្យកើតសេចក្តីគាប់ចិត្តស្និទ្ធស្នាលចំពោះគ្នា អាចលុបលាងការរឹងត្អឹង នឹងការប្រកាន់អារម្មណ៍អាក្រក់ ដែលមាននៅក្នុងមនុស្ស

ដទៃឲ្យសាបសូន្យទៅបាន ។ សូម្បីមនុស្សមានអារម្មណ៍អាក្រក់អ្នកបុគ្គិ អ្នកល្អ អ្នកតេជះ អ្នកអំណាចយសសក្តិ ប្រើកំឡាំងបង្ខាប់បញ្ហា កំផ្លាញមនុស្សមានអារម្មណ៍ល្អមិនបាន គឺអ្នកមានអារម្មណ៍ល្អ ត្រូវផ្លាញ់អ្នកមានអារម្មណ៍អាក្រក់ដោយអារម្មណ៍ល្អរបស់ខ្លួន យកឈ្នះមនុស្សចិត្តក្តៅបានដោយចិត្តត្រជាក់ត្រជំរបស់ខ្លួនជានិច្ច ជាអ្នកមានអំណាចលើគេគ្រប់យ៉ាង ។

ដូច្នេះអ្នកមានចិត្តស្ងប់ ទើបមានគុណសម្បត្តិនៅក្នុងខ្លួនច្រើនប្រការដូចយ៉ាងមានអធ្យាស្រ័យត្រជាក់ត្រជុំមិនបង្កសេចក្តីរំខាន ជាមនុស្សមានបញ្ញាឈ្លាសវៃប្រសប់និយាយគ្រប់យ៉ាង មានការសង្រួមកាយជាជំនួសការអួត តាំងខ្លួនជាកណ្តាលជំនួសការលំអៀងទៅក្នុងអគតិ រាប់អានមនុស្សដទៃដូចរាប់អានខ្លួនឯង ដាក់ខ្លួនជំនួសការវាយកំពស់ខ្លួនថាប្រសើរជាងគេទាំងអស់ មានការទុនលំទោនជំនួសការរឹងត្អឹង មានចរិយាគួរស្រឡាញ់ហើយត្រូវធម៌ធង បន្ទន់ស៊ីសៈចុះដោយការគោរព, ក្នុងគ្រាសម្បូរតែងមានទឹកចិត្តទន់ក្លូនល្អដូចផ្កាឈូក, ក្នុងគ្រាវិបត្តិ តែងមានទឹកចិត្តរឹងប៉ឹងដូចសិលាគាន់ មានកិរិយានឹងរាងជារៀបរយចំពោះជនទូទៅ លះបង់ការស្រើនយសមិននិយាយកោសគៀរ ឬ ពាក្យកសួកសៀតនរណាមួយ មិននិយាយដើមអ្នកដទៃ មានសេចក្តីករុណាចំពោះសត្វទាំងអស់ ជួយមនុស្សដែលមានទុក្ខធុរៈ ឬ ទីទាល់ក្រ ត្រដាបត្រដួស មានកាយល្អដោយការធ្វើ

ឧបការៈចំពោះអ្នកដទៃ មិនមែនល្អដោយអាភរណៈទេ មានដៃល្អដោយការបរិច្ចាគទានមិនមែនល្អដោយកងដៃ ឬ ខ្សែដៃទេ មានត្រចៀកល្អដោយការស្តាប់ត្រាប់ត្រង មិនមែនល្អដោយទំហូទេ មនុស្សបែបនេះបានថាជាអ្នកមានលក្ខណៈស្ងប់នៅពេញខ្លួន ។

អស់លោកអ្នកទាំងឡាយ មានចិត្តស្ងប់ហើយឬ? សូមពិចារណាមើលខ្លួនឯងចុះ ។ បើចិត្តលោកអ្នកស្ងប់ពិតមែនហើយ លោកអ្នកមុខជាបានឃើញលក្ខណៈស្ងប់ នៅក្នុងខ្លួនលោកអ្នក ដូចជាធ្វើ និយាយនឹងគិតអ្វី ក៏ដំណើរទៅតាមផ្លូវដែលចំរើន ដែលរៀបរយដែលជាផ្លូវដើររបស់មនុស្សស្ងប់ មានអធ្យាស្រ័យត្រជាក់ត្រជុំ នឹងសុភាពរាបសាជាដើម ។ មនុស្សដែលមានចិត្តស្ងប់ហើយ រមែងមានជីវិតពេញទៅដោយផលដ៏ប្រសើរជាអណ្តូងកើតនៃសន្តិសុខនឹងសន្តិភាព មានភូមិធម៌សម្រាប់នៅដ៏ស្ងប់រៀបរយ ។ បើនៅក្នុងពួកណា ក៏ជួយបង្កសេចក្តីត្រជាក់ត្រជុំរំលត់សេចក្តីក្តៅក្រហាយ ទុក្ខសោកម្នាញ់គ្រប់យ៉ាង នឹងនាំយកសេចក្តីរុងរឿងចំរើន សម្បូរសប្បាយសន្តិសុខ ចូលមកកាន់ពួកនោះ ។ បើទុកជាថយចេញទៅ ក៏ធ្វើឲ្យពួកដែលនៅខាងក្រោយនោះ នាំគ្នារំពឹកសរសើរគុណ ។

២— ចិត្តឱបអរសោទរ — អ្នកមានចិត្តឱបអរសោទរ ជាមនុស្សមានអធ្យាស្រ័យទូលំទូលាយ មានទឹកចិត្តអើពើមិនឃើញតែ

ប្រយោជន៍ចំពោះខ្លួន ជាមនុស្សយល់ចិត្តយល់ថ្លើមគេឯង ស្រឡាញ់រាប់អានគ្នា ជួយសង្គ្រោះឧបត្ថម្ភផ្គងផ្ដើមគ្នា មិនស្រវាយកឲ្យបានតែខាងខ្លួន មានព្រហ្មវិហារ ៤ ជាផ្លូវនៃអធ្យាស្រ័យ គឺមានមេត្តាប្រាថ្នាចង់ឲ្យអ្នកដទៃបានសុខ សូម្បីសេចក្ដីសុខដែលគេត្រូវបាននោះ ឥតបានជាផលដល់ខ្លួនក៏ដោយ ក៏តាំងចិត្តជួយឲ្យគេបានសេចក្ដីសុខសេចក្ដីចំរើនក្រៃលែងឡើងទៅ មានករុណាប្រាថ្នាចង់ជួយ មិនចង់ឲ្យគេបានទុក្ខ ឬ គេមានទុក្ខក្ដៅក្រហាយ ក៏យកចិត្តទុកដាក់ជួយឈឺឆ្អាល កំចាត់ទុក្ខវេទនា សូម្បីសេចក្ដីទុក្ខដែលគេត្រូវបាន ឬបានហើយនោះ មិនជាប់ទាក់ទងនឹងខ្លួនក៏ដោយ ក៏តាំងចិត្តជួយឲ្យគេផុតទុក្ខនោះ, មានមុទិតាបេះរីករាយសប្បាយក្នុងកាលដែលគេបានសុខចំរើន ទុកជាខ្លួនមិនបានសុខចំរើនផង ឬត្រឡប់ខូចទីទាបតូចតិចទៅជាងគេក៏ដោយ ក៏តាំងចិត្តទទួលបីតិត្រេកអររីករាយអនុមោទនាសាទរជាមួយនឹងគេ នឹងមានឧបេក្ខាមិនរីករាយក្នុងកាលឃើញគេបានទុក្ខ ទាំងមិនបន់ស្រន់ បួងសួងឲ្យគេវិនាសបាត់បង់សូម្បីអន្តរាយនោះ មិនទាក់ទាមនឹងខ្លួនឬខ្លួនត្រឡប់ឡើងថ្នាក់ខ្ពស់ហួសទៅក៏ដោយ ក៏តាំងចិត្តជាកណ្ដាលព្រងើយៗ មិនផ្ដាសាផ្ដន្ទាគេ ៗ

(មានត)

# រឿងសាមកុក

## កណ្ឌទី ១១

ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
> អ្នកវាងវៃឆ្លាសបើបានអាន
> នឹងចេះឧបាយកលបំណាន
> ទាំងមានសន្តានស្នេហាជាតិ ។

លីឈុយក៏ឲ្យយកបាយដែលផ្អូម នឹងសាច់គោស្អុយ ៗ ប្រគល់ឲ្យខ្ទីនាំយកទៅថ្វាយ ៗ ព្រះចៅហៀនតេឃើញដូច្នោះ ក៏ទ្រង់ព្រះក្រោធហើយត្រាស់ថា អាសត្វវាមើលងាយប្រមាថដល់អញខ្លាំងណាស់ ៗ

ខណៈនោះ អៀវពីវលបចូលទៅគាល់ ហើយក្រាបទូលឃាត់ថា លីឈុយមានចិត្តអាក្រក់ណាស់ គ្រានេះព្រះអង្គនៅក្នុងបង្គាប់វា ត្រូវតែខំអត់សង្កត់ព្រះទ័យសិនចុះ ៗ ព្រះចៅហៀនតេមិនឆ្លើយតបសោះ ទ្រង់ព្រះកន្សែងសោកាទាល់តែស្នងព្រះអង្គនោះទទឹកដោយទឹកព្រះនេត្រា ៗ

វេលានោះ មានមនុស្សលបចូលទៅ យកសេចក្ដីក្រាបទូលព្រះចៅហៀនតេថា មានទ័ពលើកមកទទួលស្ដេច ៗ ព្រះចៅហៀនតេប្រើខ្ទី

ឲ្យលបចេញទៅស្តាប់ការណ៍ ក៏ដឹងថាគុយគីលើកទ័ពមក ៗ ព្រះចៅហៀនគេទ្រង់ព្រះដំរិះថា "គុយគីនឹងធ្វើអន្តរាយដល់យើងហើយ" ក៏រិតតែទ្រង់ព្រះកន្សែងឡើងទៀត ទទួលបានព្រួសំឡេងក្រៅកំពែង ស្រែកហោអឺអឺង ៗ លីឈ្មុយដឹងថាគុយគីលើកទ័ពមក ក៏ផ្តុំកងទ័ពលើកចេញទៅ ទើបយករំពាត់សេះចង្អុលមុខគុយគីហើយស្រែកថា អញចិញ្ចឹមរក្សាឯងដល់ខ្នាត ហេតុម្តេចឯងត្រឡប់គិតប្រមាថធ្វើអន្តរាយអញវិញ? ៗ

គុយគីតបថា ខ្លួនឯងជាសត្រូវរាជសម្បត្តិ បានជាអញគិតសម្លាប់ឯងចេញ ៗ លីឈ្មុយថា អញអញ្ជើញស្តេចព្រះចៅហៀនគេ ចេញមករក្សាទុក ហេតុម្តេចបានជាឯងថាអញជាសត្រូវរាជសម្បត្តិវិញ? ៗ គុយគីតបថា ឯងឲ្យក្មួយហៅហានចូលទៅនាំស្តេចមក ប្រាថ្នានឹងធ្វើអន្តរាយព្រះអង្គចេញ លុះអញលើកទាហានតាមមក ឯងកែខ្លួនថានាំស្តេចមករក្សាទុក ៗ លីឈ្មុយខឹងណាស់ស្រែកថា "កុំឲ្យក្តៅក្រហាយដល់សេនាទាហានឯទៀតឡើយ ឯងនឹងអញចេញមកតទល់គ្នាតតួចុះ បើឯងឈ្នះក៏នាំយកស្តេចនៅចុះ" ថាហើយបរសេះចេញទៅប្រយុទ្ធគ្នានឹងគុយគីបាន ១០ ក្បួន មិនចាញ់មិនឈ្នះ ៗ

អៀវតីវដឹងថា អ្នកទាំង ២ កើតទោសទាស់គ្នាជាខ្លាំង ខុសពីគំនិតដែលគិតទុកនោះ ទើបនាំពួកនាហ្មឺនតូចធំប្រហែល ៦០ នាក់ ស្ទុះរូតទៅ ឃើញលីឈ្មុយគុយគីកំពុងច្បាំងគ្នា ៗ អៀវតីវស្រែកឃាត់ថា

លោកទាំងពីរកុំច្បាំងគ្នាឡើយ ខ្ញុំនឹងនាហ្មឺនទាំងអស់គ្នាមកអង្វរសុំឃាត់ឲ្យលោកទាំងពីរជានឹងគ្នាដូចប្រក្រតីទៅវិញចុះ ។ លីឈុយគុយគីបានស្តាប់ដូច្នោះ ទាំងសងខាងក៏នាំទាហានត្រឡប់ថយរៀងខ្លួន ។ អៀវតីវនាំនាហ្មឺនទាំងនោះទៅតាមឃាត់គុយគី ។ ឃើញនាហ្មឺនទាំងពួងមក ក៏បង្គាប់ទាហានឲ្យចាប់ខ្លួននាហ្មឺនទាំងអស់ទៅដាក់គុកទុក ។ នាហ្មឺនទាំងអស់ប្រកែកថា យើងទាំងអស់គ្នាគ្មានទោសខុសពីអ្វីសោះ មកនេះប្រាថ្នានឹងឃាត់ហាមលោកមិនឲ្យតាំងច្បាំងគ្នា ហេតុម្តេចបានជាយកយើងទៅដាក់គុកវិញ ។ គុយគីតបថា លីឈុយនាំយកព្រះចៅហៀនតេនឹងព្រះអគ្គមហេសីស្រីស្នំទៅឃុំឃាំងទុកខាងណោះ បានជាយើងត្រូវឃុំឃាំងអ្នកទាំងអស់ទុកខាងណេះ ។ អៀវតីវឆ្លើយថា បើលីឈុយនាំយកព្រះចៅហៀនតេទៅឃុំឃាំងទុកខាងណោះ ហើយលោកឃុំឃាំងយើងខាងណេះតើនឹងគិតធ្វើម្តេច? ។ គុយគីបានស្តាប់ខឹងណាស់ហូតគ្រប៊ីចេញប្រុងនឹងកាប់អៀវតីវ ទទួលទាហានគុយគីម្នាក់ស្ទុះទៅឃាត់ គុយគីក៏ឲ្យបើកលែងអៀវតីវនឹងជូហ៊ុចេញទៅ ក្រៅពីនោះក៏ឲ្យឃាត់ឃុំទុកក្នុងគុក ។ អៀវតីវនឹងជូហ៊ុដើរមកដល់កណ្តាលផ្លូវក៏ប្រឹក្សាគ្នាថា "យើងជានាហ្មឺនព្រះមហាក្សត្រ ទទួលបៀវត្សរ៍ដែលប្រោសព្រះរាជទាន គ្រានេះព្រះចៅហៀនតេមានព្រះគ្រោះទៅរងទុក្ខលំបាកជាទម្ងន់ណាស់ យើងនឹងក្រឡះបោលព្រះអង្គក៏ដូចមិនមានសេចក្តីកតញ្ញូសោះ ដូច្នេះត្រូវតែយើង

គិតទំនុកបំរុងផែនដី ឲ្យព្រះអង្គបានសេចក្ដីសុខតទៅទើបគួរ" និយាយហើយក៏កៀកកគ្នាយំទាល់តែដួលចុះក្នុងទីនោះ លុះដឹងស្មារតីក្រោកឡើងនាំគ្នាទៅទីលំនៅរៀងខ្លួន ។ ឯដូហ៊ីនោះក៏មានជម្ងឺឈឺស្លាប់ទៅ ។

កាលលីឈុយនឹងគុយគីតតាំងច្បាំងគ្នានោះ ក៏ចេះតែច្បាំងគ្រប់ថ្ងៃមិនឈប់ប្រហែល ២ ខែ ទាហានទាំងសងខាងសឹងស្លាប់វិនាសច្រើនណាស់ ។ ឯលីឈុយកាលនៅក្នុងបន្ទាយនោះជឿកាន់យកពាក្យ (អម៉ុតអថាវ) ។ ការសៀងឃាត់ហាមជាច្រើនគ្រាថា កុំឲ្យជឿស្ដាប់ពាក្យមនុស្សជំពូកនេះ ។ លីឈុយមិនស្ដាប់ ចង់ធ្វើអ្វី ក៏ធ្វើ (អថាវ) គ្រប់គ្រា ។

អៀវគីនាហ៊ីនក្នុងហុងដឹងដូច្នោះ បានលបចូលទៅក្រាបទូលព្រះចៅហៀនតេថា ការសៀងជាទីប្រឹក្សាលីឈុយ ការសៀងនិយាយការអ្វី លីឈុយមិនដែលធ្វើតាមសោះ ប្រហែលការសៀងមានចិត្តស្វាមីភក្តិនឹងព្រះអង្គនៅឡើយ សូមឲ្យហៅការសៀងមកគាល់ហើយត្រាស់ប្រារព្ធពីកិច្ចរាជការទាំងពួង ។ កំពុងតែនិយាយ ទទួលការសៀងចូលទៅគាល់, ព្រះចៅហៀនតេទ្រង់ឲ្យបណ្ដេញពួកខន្ទីទៅខាងក្រៅ ហើយទ្រង់ព្រះកន្សែងសោកពិលាបមានព្រះបន្ទូលនឹងការសៀងថា គ្រានេះយើងមានសេចក្ដីទុក្ខលំបាកខ្លាំងណាស់ អ្នកចូរមានចិត្តស្វាមីភក្តិជួយធុរៈការផែនដីដោយសុចរិត ជួយយកអាយុជីវិតយើងឲ្យរួចផង ។

កាសៀនក្រាបទូលព្រះឧង្ការថា សព្វថ្ងៃនេះ ទូលព្រះបង្គំជាខ្ញុំតាំងចិត្តគិតផ្ដើកដការថ្វាយស្នងព្រះតេជព្រះគុណមិនមានភ្លេចសោះ សូមព្រះអង្គកុំអាលត្រាស់ឲ្យសេចក្ដីតាំងអស់បែកផ្សាយឡើយ ការតាំងនេះហើយជាភ្នាក់ងារទូលព្រះបង្គំជាខ្ញុំនឹងគិតឲ្យសម្រេច ។ ព្រះចៅហៀនតេទ្រង់សោយព្រះទ័យ ទទួលលីឈុយកាន់គ្រប់ដើរចូលទៅ, ព្រះចៅហៀនតេក៏ស្ងួតព្រះសតិ ។

លីឈុយក្រាបទូលព្រះចៅហៀនតេថា គ្រានេះ គុយគីគិតក្បត់នឹងព្រះអង្គ បានជាវាចាប់យកនាហ៊ីនប្រើនទាក់ទៅដាក់គុកទុក ហើយវានឹងមកចាប់ព្រះអង្គយកទៅទៀត ដោយសារទូលព្រះបង្គំជាខ្ញុំនាំចង្វើរព្រះអង្គមក បានជាព្រះអង្គរួចអំពីភ័យនេះ ។ ព្រះចៅហៀនតេយល់ថាពិតមែន ក៏គំនាប់លីឈុយហើយត្រាស់ថា ដែលអ្នកបានជួយឧបត្ថម្ភយើងដូច្នេះ យើងមានអំណរគុណក្រៃលែងបំផុតគ្មាន ។ លីឈុយក៏ថ្វាយបង្គំលាទៅវិញ ។

ខណៈនោះហងហ៊ូហៀបចូលទៅគាល់ព្រះចៅហៀនតេ ។ ទ្រង់ព្រះដំរិះដឹងថា "ហងហ៊ូហៀបមានសតិបញ្ញា ហើយធ្លាប់នៅស្រុកជាមួយគ្នានឹងលីឈុយ" ទើបទ្រង់មានឡាយព្រះហស្តលេខាឲ្យទៅហាមឃាត់លីឈុយគុយគីកុំឲ្យទាស់ទែងគ្នាតទៅ ។ ហងហ៊ូហៀបទទួលយកឡាយព្រះហស្ត ហើយចូលទៅរកគុយគីកងបន្ទាយ ។ គុយគីឃើញឡាយ

ព្រះហស្ដហើយនិយាយថា បើលីឈុយបើកលែងព្រះចៅហៀនគេចេញ, យើងនឹងលែងពួកនាហ៊ីនដែលឃុំទុកនោះចេញដែរ យើងនឹងលីឈុយក៏នឹងប្រកតីគ្នាតទៅ ។ ហងហ៊ូហៀបបានស្ដាប់ហើយ លាត្រឡប់ទៅរកលីឈុយកុងបន្ទាយនិយាយថា ខ្ញុំនឹងលោកជាពួកនៅស្រុកជាមួយគ្នា បានជាព្រះករុណាប្រើខ្ញុំឲ្យកាន់ឡាយព្រះហស្ដនេះ មកហាមឃាត់លោកនឹងគុយគីកុំឲ្យតតាំងច្បាំងគ្នា ឯខាងគុយគីព្រមស្ដាប់ព្រះត្រាស់អស់ហើយ នៅឡើយតែខាងលោកឯនេះនឹងថាដូចម្ដេច ? ។ លីឈុយតបថា យើងបានទំនុកបំរុងមក ៤ ឆ្នាំហើយ សេចក្ដីគាប់ប្រសើរក៏មានជាច្រើន, គុយគីគ្រាន់តែជាមនុស្សកំណាចដើរលួចសេះ មកបានឡើងដល់ប៉ុណ្ណេះ មិនគួរនឹងប្រកាន់ខ្លួនជាធំ ហើយយកនាហ៊ីនទាំងពួងទៅឃុំទុកក្នុងគុក ហើយប្រទូសរ៉ាយដល់យើងៗ នឹងសម្លាប់វាចេញឲ្យបាន ។

ហងហ៊ូហៀបតបថា កាលគ្រាតាំងគុះលើកខ្លួនជាធំនោះមិនបានធ្វើឲ្យទាហានម្នាក់ខូចសោះ តែបាបគ្រោះព្រោះលីប៉ោគ្មានកតញ្ញូ លបសម្លាប់តាំងគុះបាន សព្វថ្ងៃនេះអាណាខែត្រក្នុងក្រៅនៅមិនទាន់រាបទាបទេ លោកកុំអាលគ្នេរថាខ្លួនលោកជាធំជាងគេនោះឡើយ, ប្រការមួយបងប្អូនញាតិសន្ដានរបស់លោក បានធ្វើរាជការជានាហ៊ីនមុខមន្ត្រីទាំងអស់ ព្រោះព្រះចៅហៀនគេទ្រង់ប្រោសប្រទានឲ្យលោកមានបណ្ដាស័ក្តិជាធំផុតខ្នាត ហេតុម្ដេចលោកយកព្រះអង្គទៅបង្ខាំងទុកដោយអំណាច,

គុយគីឃើញលោកធ្វើដូច្នេះ បានជាយកនាហ្មឺនទាំងនោះទៅឃុំក្នុងគុក ដូចគ្នា លោកទាំងពីរនេះសុទ្ធតែជាអ្នកទំនុកបំរុងផែនដីរៀងមក ដែលមកធ្វើដូច្នេះ មិនត្រូវសោះ នឹងថាខាងណាខុសខាងណាត្រូវក៏នៅថាមិនបាន សូមឲ្យលោកវិះជ្យានគិតមើលចុះ ។

លីឈុយបានឮដូច្នោះក៏ខឹងលើសលុប ចាប់យកគ្រឹកាន់ហើយស្រែកគំហកថា ព្រះចៅហៀនតេប្រើខ្លួនឲ្យមកទ្រគោះបោះបោកឲ្យយើងឬ បានជាខ្លួនហ៊ាននិយាយដូច្នេះ? យើងនឹងកាត់ក្បាលខ្លួនឥឡូវនេះ ។ អៀវហងឃើញដូច្នោះក៏ឃាត់ហាមថា ការដែលគុយគីនឹងលោកទាស់ទែងគ្នាជាធំមិនទាន់ដឹងដូចម្តេច គេចមកចង់សម្លាប់ហងហ៊ូហៀបជាព្រះរាជបំរើទៀតមិនគួរសោះ បើសេចក្តីនោះដឹងទៅដល់អាណាខេត្តខាងក្រៅហើយ មិនលែងឡើយនឹងលើកទ័ពមកជួយខាងគុយគី ធ្វើឲ្យលោកខ្ចបខ្ចីមិនខាន ។ កាសៀងក៏ចូលទៅឃាត់ហាមតាមសំដីអៀវហងទៀត, លីឈុយក៏មិនបានសម្លាប់ហងហ៊ូហៀប, កាសៀងក៏នាំហងហ៊ូហៀបចេញទៅ ។ ហងហ៊ូហៀបស្រែកប្រកាសថា លីឈុយធ្វើការអាក្រក់ណាស់ មានព្រះតម្រាស់បង្គាប់មកក៏មិនស្តាប់សោះ, ដែលធ្វើដូច្នោះប្រែងនឹងដណ្តើមយករាជសម្បត្តិហើយ ។

ទុមៅឮហើយក៏ឃាត់ហាមកុំឲ្យនិយាយថាដូច្នេះ ក្រែងនឹងមានអន្តរាយមកដល់ខ្លួន ។ ហងហ៊ូហៀបមិនស្តាប់ស្រែកគំហកថា “ខ្លួនជា

មន្ត្រីស៊ីប្រាក់បៀវត្សរ៍ដែលប្រោសព្រះរាជទាន ឥឡូវនេះព្រះចៅហៀនគេមានទុក្ខលំបាកផ្ទាល់ព្រះអង្គដូច្នេះ យើងជាខ្ញុំរាជការមិនត្រូវស្តាយជីវិត ត្រូវតែគិតតបស្នងព្រះគេជគុណ ខ្លួនមកនិយាយដូច្នេះ ជាមនុស្សអកតញ្ញូណាស់ ឬខ្លួនជាពួកអាក្បត់ដែរ" ថាហើយក៏ស្រែកជេរលី-ឈុយជាពាក្យអាស្រូវកាសហើយដើរទៅ ។

ព្រះចៅហៀនគេទ្រង់ជ្រាប ក៏ឲ្យហៅហានហ៊្វីហៀបចូលទៅគាល់ ហើយត្រាស់ថា អ្នកនឹងនៅក្នុងស្រុកក្រុងនេះមិនបានទេ អន្តរាយនឹងមានដល់ខ្លួនអ្នក បើដូច្នេះត្រូវតែដោះចេញឲ្យផុត ចូរទៅនៅស្រុកស៊ីឡ្យុងចុះ ។ ហានហ៊្វីហៀបបានស្តាប់ព្រះតម្រាស់ក៏ក្រាបថ្វាយបង្គំលា ហើយនិយាយបបួលពួកទាហានលីឈុយដែលមកពីស្រុកស៊ីឡ្យុងថា លីឈុយគ្រានេះធ្វើការទុច្ចរិតគិតក្បត់ផែនដីហើយ អ្នកទាំងឡាយនៅជ្រកកោននឹងវាមិនបានទេ បើនៅហើយអន្តរាយទាំងពួងក៏គង់នឹងមានដល់ខ្លួន ។ ទាហានទាំងពួងបានឮហានហ៊្វីហៀបប្រាប់ដូច្នោះ ក៏ភិតភ័យណាស់ នាំគ្នារត់ចេញពីផ្ទះលីឈុយទៅជាច្រើន ។

លីឈុយបានដឹងដំណើរក៏ប្រើអង្គៀងលើកទាហានតាមចាប់ហាន-ហ៊្វីហៀបមកវិញ ។ អង្គៀងលើកតាមទៅដល់កណ្តាលផ្លូវក៏គិតថា "ហានហ៊្វីហៀបជាមនុស្សសុចរិតពិតត្រង់នឹងផែនដី បើតាមចាប់ខ្លួនបានមក លីឈុយក៏ឲ្យសម្លាប់ជាអសារឥតការ សេចក្តីគេហោនិន្ទាក៏នឹងមានដល់ខ្លួន

យើង» គិតហើយក៏លើកទ័ពត្រឡប់មកវិញ ហើយចូលទៅប្រាប់លីឈុយ ថា ខ្ញុំបាទបានតាមហាងហ៊្វូហៀបទៅរកមិនឃើញទេ ។ លីឈុយមិនបានថា ប្រការម្ដេច ។ ខណៈ នោះកាសៀងចូលទៅក្រាបបង្គំគាល់ព្រះចៅហៀនតេ ហើយទូលថា លីឈុយធ្វើរាជការគ្រានេះ ជាផ្លូវប្រទូស-ព៌យអាក្រក់នឹងផែនដីខ្លាំងណាស់ អស់សេនាទាហានសឹងតែប្រែចិត្តរត់ចោលលីឈុយជាច្រើន សុំឲ្យមានព្រះតម្រាស់ជាឧបាយយកចិត្តតាំងឲ្យលីឈុយឡើងជាមហាឧបរាជចុះ ទូលព្រះបង្គំជាខ្ញុំនឹងសុំតាំងចិត្តគិតការតទៅ ។ ព្រះចៅហៀនតេទ្រង់យល់ឃើញត្រូវផង ក៏តាំងលីឈុយជាមហាឧបរាជ ។ លីឈុយមានសេចក្ដីសោមនស្សណាស់ហើយថា "យើងបានឡើងទីគ្រានេះក៏ព្រោះ (អម៉ុតអថាវ) ជួយ" ថាហើយយកមាសប្រាក់នឹងគ្រឿងសំលៀកបំពាក់ឲ្យដល់ (អម៉ុតអថាវ) ជាច្រើន ។ ឯទាហានឯទៀតលីឈុយនឹងបានឲ្យរបស់អ្វីក៏ទេសោះ ។

អៀវហាងឃើញដូច្នោះខឹងណាស់ និយាយនឹងសងកោថា យើងជាទាហានលីឈុយបានធ្វើការសឹកសង្គ្រាមមក ក៏ច្រើនដងច្រើនគ្រា លីឈុយនឹងបានឲ្យរង្វាន់ជាគុណបំណាច់អ្វីគ្មានសោះ លើកយករបស់ទៅបំពេញឲ្យ (អម៉ុតអថាវ) វិញ ។

សងកោតបថា យើងក៏មានសេចក្ដីតូចចិត្តណាស់ដែរ យើងនឹងគិតសម្លាប់លីឈុយចេញ ហើយចូលទៅគាល់បំរើព្រះចៅហៀនតេវិញ

ប្រសើរជាង ។ អៀវហង់យល់ឃើញត្រូវថា យើងនឹងទៅបញ្ចុះបញ្ចូលទាហានឲ្យបានច្រើន វេលា ៣ ថ្ងៃនេះ អ្នកនៅខាងក្នុងត្រូវប្រុងយកភ្លើងដុតបន្ទាយឲ្យឆេះឡើង យើងលើកទាហានចូលមកចាប់លីឈុយសម្លាប់ចេញ ។ សង់កោយល់ព្រម អៀវហង់ក៏ចេញទៅពន្យល់ទាហានក្រៅបន្ទាយ ។ មានទាហានម្នាក់ដឹងសេចក្ដីក៏ចូលទៅប្រាប់លីឈុយតាមដំណើរអៀវហង់នឹងសង់កោគិតគ្នានោះ ។ លីឈុយឲ្យចាប់យកខ្លួនសង់កោបាន ហើយនាំទៅសម្លាប់ ។ ឯអៀវហង់ហ៊ឹកហាត់ទាហានបាន ចាំមើលដល់យាម ២ ប្លាយ មិនបានឃើញពន្លឺភ្លើងឆេះឡើងសោះក៏ឲ្យទាហានទាំងអស់សម្ងំនៅ ។ ខណៈនោះលីឈុយលើកទាហានចេញពីបន្ទាយចួបប្រទះនឹងកងទ័ពអៀវហង់ ក៏តាំងច្បាំងគ្នា ។ ទាំងសងខាងមានរបួសពិការស្លាប់ជាច្រើន ។ អៀវហង់ឃើញថាកម្លាំងនឹងតទល់ពុំឈ្នះ ក៏នាំទាហានដែលសល់នោះរត់ចេញទៅទិសឯលិច ។

ឯគុយគីលើករេហ៍ពលមកតតាំងច្បាំងគ្នា នឹងទ័ពលីឈុយគ្រប់ៗថ្ងៃ, ទាហានលីឈុយស្លាប់រលស់អស់ទៅ ដែលសល់នៅក៏រត់ចេញទៅខ្លះ ។

(មានត)

# ព្រះរាជពង្សាវតារប្រទេសកម្ពុជា

## ភាគទី ២

## សម័យនគរធំ

ឧកញ៉ាទេពពិទូរ ឈឹម-ក្រសេម រៀបរៀង

(តមក)

---

**ការចេញនៃព្រះមហាក្សត្រិយ៍**— ការចេញនៃព្រះមហាក្សត្រិយ៍នោះ គឺចេញចាកព្រះរាជនិវេសន៍ទៅឋានរង្គសភា ដ៏តាំងនៅក្នុងព្រះបរមរាជវាំង នឹងចេញទៅក្រៅព្រះបរមរាជវាំង តាមកាល ៗ

រង្គសភាក្នុងទីនេះ គឺជាទីប្រជុំក្រាបបង្គំគាល់របស់អ្នករាជការនឹងបណ្ដារាស្ត្រ ៗ អ្នករាជការជាន់ខ្ពស់មានសេនាបតីជាដើម ត្រូវចូលទៅក្រាបបង្គំគាល់នៅទីនោះជានិច្ចរាល់ថ្ងៃ, កាលបើមានហេតុការណ៍អ្វីដែលគួរក្រាបបង្គំទូលដើម្បីទ្រង់ជ្រាប ក៏យកសេចក្ដីក្រាបបង្គំទូលឡើង ៗ ចំណែកពួករាស្ត្រ កាលអ្នកណាមួយកើតទុក្ខពុំសុខចិត្តពីរឿងអ្វី ហើយត្រូវការសុំព្រះរាជវិនិច្ឆ័យ ក៏ត្រូវនាំគ្នាចូលទៅកាន់រង្គសភា យកសេចក្ដីក្រាបបង្គំទូលស្នើតាមដំណើរការណ៍, កាលទ្រង់ព្រះសណ្ដាប់ពាក្យស្នើហើយ ក៏ទ្រង់វិនិច្ឆ័យសម្រេចតាមគួរនឹងការណ៍ ៗ ប្រសិនគ្មានរឿងការផ្ទាល់ខ្លួន នោះនឹងចូលទៅគាល់ដើម្បីឃើញព្រះអង្គ ឬដើម្បីស្ដាប់សេចក្ដីព្រះរាជវិនិច្ឆ័យក៏បាន ៗ ព្រះរាជពិធីធំៗ ដែលជាចំពូកព្រះរាជពិធីត្រា-

ទសមាស ក៏ត្រូវប្រជុំធ្វើនៅទីនេះ, ក្រៅពីពួកបរទេសដែលត្រូវការចូលក្រាបបង្គំគាល់ ក៏ត្រូវចូលគាល់នៅក្នុងរដ្ឋសភានេះដែរ, ធៀបតាមទំនៀមទម្លាប់បច្ចុប្បន្ន ដូចព្រះទីនាំងទេវាវិនិច្ឆ័យ ។

រដ្ឋសភាសម័យក្រុងយសោធរៈបុរៈ តាំងនៅខាងមុខទ្វារព្រះបរម-រាជវាំងជាប់ក្នុងទីធំនៅខាងលិចទីព្រះលាន, សព្វថ្ងៃនៅមានសំណាសសំណល់ជាកស្តុតាង គឺផ្ទៃទី ទីងសសរខ្ទះ ។ តាមផែនទីនោះសង្កេតឃើញថា រូបរដ្ឋសភានោះ សណ្ឋានប្រហែលពេងវែងតាំងនៅទទឹងថ្ងៃ បណ្តោយប្រមាណជាង ១០០ ម៉ែត្រ ទទឹងប្រមាណជាង ២០ ម៉ែត្រ គេលើកជាផ្ទៃខ្ពស់ឡើងប្រមាណជាង ១ ម៉ែត្រ ហើយទើបសង់រដ្ឋសភាលើផ្ទៃនោះ ។ តួរដ្ឋសភា សសរថ្ម ៤ ជួរ ប្រកសំណ ឬក្បឿង? មានជណ្តើរឡើងពីខាងមុខ ៣ ពីខាងក្រោយ ៣ មានទ្វារ ៦ តាមចំនួនជណ្តើរ មានបង្អួចគ្រប់តាមចន្លោះសសរ ទ្វារនឹងបង្អួចសុទ្ធតែបិទមាស មានកញ្ចក់ធ្ងះធំៗ ដាក់ដំកលលើសសរថ្ម ៤ ជួរអមបង្អួច អំបាលនោះផង ។ តាមដំហារផ្ទៃទីពីខាងមុខ គឺសង់ខាងជណ្តើរទាំងបី ប្រដាប់ដោយក្បាច់រចនា នឹងរូបភាពផ្សេងៗ មានរូបដំរីនឹងសីហៈជាដើម ។

រាជបល្ល័ង្កសម្រាប់ស្តេចគង់ តាំងនៅក្នុងរដ្ឋសភានេះ តែតាំងនៅត្រង់ណា មិនអាចដឹងបានជាប្រាកដ, បើដោយសន្និដ្ឋានឃើញថាតាំងនៅត្រង់កណ្តាលល្វែងខាងត្បូងបំផុត បែរមុខទៅខាងជើង តាមបណ្តោយ

រដ្ឋសភា, អ្នកចូលគាល់អង្គុយពីខាងជើង បែរមុខទៅរកពដបល្ល័ង្ក ។ ពដបល្ល័ង្កនោះបាំងដោយសំពត់កាំមញីក្រហមជាព្រះសាណាំយា តែមានមុខសម្រាប់បើកបិទទាំង ៤ ទិស, លើផ្ទៃពដបល្ល័ង្កក្រាលស្បែកពដសីហ៍ដែលជារបស់មានមកយូរហើយ, ផ្លូវឡើងទៅលើពដបល្ល័ង្ក មានតែពីខាងក្រោយ ១ ផ្លូវប៉ុណ្ណោះ ។

ស្ដេចចេញប្រាំងរដ្ឋសភា — រាល់ៗថ្ងៃ បើស្ដេចមិនប្រឈួចមិនបានស្ដេចយាងទៅក្រៅព្រះបរមរាជវាំងទេ រមែងស្ដេចយាងទៅប្រាំងរដ្ឋសភា ក្នុងមួយថ្ងៃ ២ វេលាជាដរាប ។ តាមសណ្ដាប់ព្រះមហាក្សត្រិយ៍ក្នុងសម័យនោះ វេលាស្ដេចនឹងចេញចាកព្រះរាជនិវេសន៍ រមែងទ្រង់កាន់ព្រះខ័នមាសខ្ជាប់នៅព្រះហស្ដជានិច្ច ហើយរាល់ពេលស្ដេចចេញ គេតែងប្រគំភ្លេង ស្នូរភ្លេងឮល្វើយៗ មកដល់រដ្ឋសភា លុះផុតសព្ទភ្លេងហើយ ទ្រង់ឡើងគង់វិមាស មានស្ត្រីក្រមុំ ៤ នាក់សែងនឹងមានពួកស្ត្រីជាតម្រួតហែមុខ មានពួកស្ត្រីក្រមុំកាន់គ្រឿងរាជូបភោគហែតាមក្រោយ ។ ក្នុង ១ ស្របក់ ក៏ស្ដេចយាងមកដល់រដ្ឋសភា, ខណៈនោះ មានពួកព្រាហ្មណ៍ផ្លុំស័ង្ខទទួលថ្វាយជ័យ មានកុមារី ២ នាក់ឡើងទៅសើយបើកព្រះសាណាំយាលើពដបល្ល័ង្ក, ផុតសំឡេងស័ង្ខហើយស្ដេចឡើងគង់លើពដបល្ល័ង្ក, ពួកមន្ត្រីខុំរាជការទាំងបណ្ដាអ្នកចូលគាល់ទាំងប៉ុន្មានថ្វាយបង្គំព្រមគ្នា ស្រេចហើយទើបព្រះមហាក្សត្រិយ៍ត្រាស់សួរពីសុខទុក្ខ នឹងជំនុំការផែនដីតទៅ ។ (មានត)

# រឿងអារ័ក្សថ្លែងរឿងម្ភៃប្រាំ

## លោកសាង-សាវ៉ឺត លេខានុការ ក្រសួងហិរញ្ញវត្ថុ

*ប្រែពីភាសាបារាំងមកជាខ្មែរ*

(តមក)

## រឿងទី ២

នៅឆ្នេរទន្លេជមនា[១] (Jamna) មានទីក្រុងមួយឈ្មោះដាម៉ូថាល (Darmothal) ។ ស្តេចនៃក្រុងនេះព្រះនាម គុណាធីប (Gunadhip), នៅក្នុងសង្កាត់ក្រុងនេះ មានព្រាហ្មណ៍ម្នាក់ឈ្មោះកេស្ហាវ (Keshav) បានប្រព្រឹត្តសមណធម៌ និង បំពេញកិច្ចព្រះសាសនានៅតាមឆ្នេរទន្លេនោះ ។ បុត្ររបស់គាត់ឈ្មោះនាងមធុ-មាលិតី (Madhu-Maliti) មានរូបល្អអស្ចារ្យ ហើយមានអាយុដល់ខែត្រគ្រប់ការផង ។ ឯមាតាបិតាបងប្អូនក៏យល់ថា នាងល្អដែរ ។

មានថ្ងៃមួយ បិតារបស់នាងបានទៅក្នុងពិធីមង្គលការរបស់មិត្តភក្តិម្នាក់, ចំណែកឯបងរបស់នាងបានទៅអានគម្ពីរនៅផ្ទះអាចារ្យម្នាក់ ដែលនៅក្នុងភូមិមួយជិតនោះ ។ កាលជនទាំងពីរនេះចេញផុតទៅ កូនព្រាហ្មណ៍ម្នាក់បានទៅដល់ផ្ទះនាង ។ ឯមាតារបស់នាង កាលសង្កេតឃើញដំឡៃ និងរូបឆោមល្អឆើតឆាយរបស់ព្រាហ្មណ៍កម្លោះនោះ ក៏និយាយឡើងថា "ខ្ញុំនឹងឲ្យកូនស្រីខ្ញុំទៅអ្នក" ។

---

១ ឋប់តែ យមុនា ទេដឹង? ។

ចំណែកខាងឪពុកនាងបានសន្យាថា នឹងឲ្យនាងទៅព្រាហ្មណ៍កំលោះម្នាក់ទៀត, បងប្រុសរបស់នាង ក៏បានប្ដេជ្ញាថា នឹងឲ្យនាងទៅព្រាហ្មណ៍ម្នាក់ទៀត ដែលគេព្រមឲ្យប្អូនស្រីរបស់គេមកខ្លួនវិញដែរ ។ លុះកន្លងទៅប្រាំបីថ្ងៃ ជាខាងក្រោយមក ឪពុកនឹងកូនប្រុស បាននាំយុវជនទាំងពីរមកផ្ទះខ្លួន ក៏ស្រាប់តែឃើញបុរសទី៣នៅលើផ្ទះ ។ បុរសទី១ ឈ្មោះត្រិពិក្រម (Tribikram) ទីពីរឈ្មោះពាមាន (Baman), ទីបីឈ្មោះមធុសូទាន (Madhusudan) ។ បុរសទាំងបីរូបនេះ សុទ្ធសឹងតែមានរូបល្អ ទាំងចំណេះវិជ្ជានឹងប្រាជ្ញាក៏ស្មើៗគ្នា ។ ព្រាហ្មណ៍បិតាលុះបានឃើញបុរសទាំងនេះ ដែលមានបំណុចបំណងត្រង់គ្នាក៏រំពឹងគិតថា ស្ត្រីតែម្នាក់ មានបុរសអ្នកប្រតិព័ទ្ធផងដល់ទៅបីនាក់ ដូច្នេះតើអញគួរឲ្យអ្នកណា ? មិនឲ្យអ្នកណា ? ខាងគ្រួសារអញ៣នាក់ បានព្រមព្រៀងឲ្យទៅម្នាក់ៗរួចទៅហើយ, នេះជាករណីដ៏ប្លែកបំឡែកណាស់ តើអញនឹងត្រូវដែលកយ៉ាងណាទៅ? ។ ក្នុងខណៈដែលគាត់កំពុងអន្ទុយជញ្ជ្រឹងដូច្នេះ ទទួលមានពស់ពិសមកចឹកបុត្រីគាត់ស្លាប់ទៅ ។

លុះបានដំណឹងពីមរណភាពនេះ ឪពុករបស់នាង បងប្រុសរបស់នាង នឹងបុរសសាមីខ្លួនទាំង ៣ នាក់, រួមជា ៥ នាក់ បានព្រមព្រៀងគ្នាទៅស្វែងរកគ្រូអាលម្ពាយទាំងឡាយ ដែលខ្លាំងពូកែអាចបន្សាបអាសិរពិសឲ្យសាបសូន្យទៅបាន ដោយអំណាចបុទ្ធិនៃមន្ត ។ ជនទាំង ៥ នាក់

លុះបានចាត់ការព្យាបាលបែបនេះសព្វគ្រប់ទៅហើយ ជីតាក៏មិនបាន ត្រឡប់រស់ឡើងវិញដូចបំណងសោះ ។ ក្នុងគ្រូអំបាលនោះ គ្រូទី ១ បានថ្លែងហេតុថា "មនុស្សទីមួយៗ ដែលត្រូវពស់ចឹកក្នុងថ្ងៃទី ៥ ទី ៦ ទី ៨ ទី ៩ និងទី ១៤ គ្រូមិនអាចនឹងព្យាបាលឲ្យរស់ឡើងវិញទេ" ។ គ្រូទី ២ ថ្លែងថា "ជនណាត្រូវពស់ចឹកក្នុងថ្ងៃសៅរ៍ ឬថ្ងៃអង្គារ គ្រូមិនអាចនឹងព្យាបាលឲ្យរស់ឡើងវិញឡើយ" ។ គ្រូទី ៣ អធិប្បាយថា: "ពស់ចឹកពិសចាប់ក្នុងថ្ងៃទាំងប៉ុន្មាន ដែលនៅក្នុងអំណាចតារាពេហិនី (Rôhini) មាឃ (Magha, អាស្ហបស្ន (Ashpsna) ពិស្ហកន (Bishakna) មូល (Mul) និងក្រិតិតៈ (Kritita) គឺជាពិសដែលបណ្ដាលឲ្យស្លាប់រហូតលែងរស់វិញ" ។ គ្រូទី ៤ បានបញ្ជាក់ថា "បើកាលណាអវយវៈណាមួយ ដូចយ៉ាងបបូរមាត់ក្រោម ថ្គាម ក ពោះ ឬ សរសៃពោះ ត្រូវពិសឡើងដល់ហើយ មនុស្សមិនអាចនឹងជាសះសេចក្ដីស្លាប់ឲ្យរស់ឡើងវិញបានឡើយ"។ គ្រូទី ៥ ថា "ទោះបីខ្លួនលោកជាព្រះព្រហ្មវិញក៏ដោយ មិនអាចឲ្យលោករស់បានឡើយ" ។ តើយើងនឹងធ្វើម្ដេចកើត? យើងសូមលាអ្នកសិនហើយ សុំឲ្យអ្នកគិតគូរធ្វើបុណ្យឈាបនកិច្ចតាមទម្លាប់ទៅចុះ ។

លុះអធិប្បាយរួចហើយ គ្រូអាលម្ពាយទាំងឡាយនោះក៏ថយខ្លួនចេញទៅ ។ ចំណែកឯព្រាហ្មណ៍បាននាំយកសពនាងទៅកាន់ទីប៉ាឆាមួយ ហើយបានចេញទៅបាត់ទៅ ក្នុងកាលក្រោយដែលដុតខ្មោចរួច ។

ក្រោយមក បុរសទាំងបីត្រឡប់មកដល់វិញ, បុរសទី ១ បានប្រមូលយកធាតុទាំងប៉ុន្មានទៅទីប៉ាឆានោះខ្ចប់យកទៅ ហើយតាំងខ្លួនជាអ្នកដើរសុំទាន ៗ បុរសទី ២ បានប្រមូលយកផេះខ្ចប់បានមួយកញ្ចប់ ហើយបានសង់ខ្ទមមួយសំណាក់នៅក្នុងទីនោះ ៗ បុរសទី ៣ បានយកស្បៀងមកស្ពៀកហើយស្ពាយថង់យាម ១ ដើរត់ទៅពីស្រុកមួយទៅស្រុកមួយ ៗ

ក្នុងថ្ងៃមួយ បុរសទី ៣ នេះបានទៅដល់ប្រទេសមួយហើយបានចូលទៅផ្ទះព្រាហ្មណ៍ម្នាក់ ដើម្បីសុំអាហារបរិភោគ ៗ ឯព្រាហ្មណ៍ម្ចាស់ផ្ទះ ក៏បានអញ្ជើញឲ្យចូលបរិភោគបាយជាមួយផង ៗ ព្រាហ្មណ៍អ្នកដំណើរ លុះបានឮអ្នកម្ចាស់គ្រឹះស្ថានអញ្ជើញដូច្នោះ ក៏ចូលទៅអង្គុយលើផ្ទះ ៗ កាលណាម្ហូបអាហាររៀបចំស្រេចហើយ ម្ចាស់ផ្ទះឲ្យព្រាហ្មណ៍នោះលាងដៃលាងជើង ហើយនាំទៅឲ្យអង្គុយក្នុងបន្ទប់មួយទាំងខ្លួនឯងក៏អង្គុយនៅទីនោះដែរ ៗ ឯភរិយាអ្នកម្ចាស់ផ្ទះក៏មកបំរើជនទាំងពីរ, កាលបរិភោគបាយបានប្រមាណពាក់កណ្ដាល ស្រាប់តែកូនប្រុសតូចរបស់គាត់ក៏យំឡើង ហើយចាប់ដាយសំពត់របស់ម្ដាយវា ទង់ទាញទុកមិនឲ្យទៅណា ៗ ឯម្ដាយខំប្រានប្រឡេះ តែកូននោះមិនព្រមលែងសោះ, នាងលួងលោមព្រមទាំងបញ្ឆោតគ្រប់យ៉ាងហើយក៏នៅតែយំ, នាងព្រាហ្មណីខឹងក៏ចាប់កូននោះបោះទៅក្នុងគំនរភ្លើង ៗ ឆេះទៅជាផេះអស់ទៅ ៗ

ព្រាហ្មណ៍អ្នកដំណើរកាលឃើញដូច្នោះ តឹងទ្រូងខ្លាំងណាស់ដកដង្ហើមធំ ហើយក្រោកឈរឡើង ៗ អ្នកម្ចាស់ផ្ទះក៏សាកសួរអំពីហេតុដែលព្រាហ្មណ៍នេះមិនបរិភោគបាយ ៗ ព្រាហ្មណ៍ឆ្លើយថា "តើអ្នកណាមួយហ្ន៎ អាចបរិភោគលេបរួចបាន បើនៅក្នុងផ្ទះមានអំពើយ៉ាងឃោរឃៅដូច្នេះ?" ៗ

ម្ចាស់ផ្ទះ លុះបានឮដូច្នោះ ក៏ក្រោកឈរឡើងដែរ ហើយដើរចូលទៅក្នុងបន្ទប់មួយទៀត យកក្បួន ១ ដែលជាតំរាសម្រាប់ប្រោះជីវិតដែលស្លាប់ហើយ ទើបស្វាធ្យាយទំនាយមន្តមួយស្របក់ទៅ, កុមារតូចនោះក៏រស់ឡើងវិញយ៉ាងអស្ចារ្យ ៗ ចំណែកឯព្រាហ្មណ៍ដែលជាសាក្សីនៃការចំឡែកនេះ ក៏រំពឹងគិតក្នុងចិត្តឯងថា "ប្រសិនជាអញបានក្បួននេះអញនឹងប្រោះស្រីសង្សារកំណាន់ចិត្តរបស់អញឲ្យរស់ឡើងវិញបានជាប្រាកដ" ៗ កាលគិតដូច្នោះហើយ គាត់ក៏បរិភោគបាយតទៅទៀត ហើយសំណាក់នៅក្នុងទីនោះ ៗ

លុះដល់រាត្រី កាលបរិភោគអាហារល្ងាចហើយ រៀងខ្លួនក៏ដើរតម្រង់ទៅរកគ្រែដេកដោយសព្វខ្លួន ៗ ព្រាហ្មណ៍អ្នកដំណើរចូលទៅសម្រាកក្នុងបន្ទប់មួយក្នុងផ្ទះនោះ ហើយនិយាយសន្ទនាគ្នាពីនេះពីនោះ ដរាបដល់ភាគធំនៃរាត្រីកន្លងទៅ ក៏លង់លក់ទៅ តែព្រាហ្មណ៍អ្នកដំណើរ មិនព្រមដេកឲ្យលក់ គ្រាន់តែសម្ងំធ្វើហាក់ដូចជាដេកលក់, កាលគាត់ដឹងថា

គេដេកលក់អស់ហើយ ក៏ក្រោកឡើងលបចូលទៅក្នុងបន្ទប់ ១ ដែលទុកក្បួនព្រោះ លួចយកបានហើយ ក៏រត់ទៅក្នុងកព្រៃនោះ ធ្វើដំណើរទៅយ៉ាងស្រួតរួត តែគង់វេលាជាច្រើនថ្ងៃ ទើបទៅដល់ទីប៉ាឆាដែលគេដុតសពធីតាព្រាហ្មណ៍ បានឃើញព្រាហ្មណ៍ពីរនាក់ទៀត កំពុងនិយាយជជែកគ្នា ៗ លុះព្រាហ្មណ៍ទាំងពីរក្រឡេកឃើញ ក៏ដើរចូលមកសួរយ៉ាងពក់ភាក់ថា: "ចូរអ្នកប្រាប់យើងមើល! ព្រោះអ្នកបានត្រេចស្វះស្វែងពីស្រុកមួយទៅស្រុកមួយ តើអ្នកបានចេះដឹងវិជ្ជាអ្វីខ្លះ" ។ ព្រាហ្មណ៍នោះឆ្លើយថា "ខ្ញុំចេះមន្តព្រោះមនុស្សស្លាប់ឲ្យរស់ឡើងវិញ" ។ អ្នកទាំងពីរថា "ល្អហើយ បើអ្នកបានរៀនមន្តដូច្នោះមក ចូរអ្នកព្រោះនារីដែលយើងស្រឡាញ់ទៅមើល" ។ ព្រាហ្មណ៍នោះបង្គាប់ថា "ចូរអ្នកទាំងពីរប្រមូលផេះនឹងឆ្អឹងរួមមួយគំនរឡើង ខ្ញុំនឹងព្រោះឥឡូវនេះ" ។ អ្នកទាំងពីរក៏ម្នីម្នាប្រមូលបានភ្លាម, ព្រាហ្មណ៍ក៏យកគម្ពីរមន្តមកសូត្រសែកជាសំមួយស្របក់ នាងនារីក៏រស់កនមានជីវិតក្រោកឈរឡើងនៅចំពោះមុខ ៗ

ប៉ុន្តែព្រះកាមបានធ្វើអ្នកទាំងបីឲ្យខ្វាក់ទៅ ហើយក៏ចេះតែឈ្លោះប្រកែកដណ្តើមនារីគ្នា ៗ

កាលអារក្សនិយាយដំណាលមកដល់ត្រង់នេះ ក៏បែរទៅទូលសួរព្រះមហាក្សត្រិយ៍ថា "សូមទ្រង់ព្រះមេត្តាប្រោស! សូមព្រះអង្គទ្រង់វិនិច្ឆ័យមកមើល! ក្នុងជនបីនាក់នោះ តើនរណាត្រូវបាននាង?" ។

ព្រះមហាក្សត្រិយ៍ត្រាស់ថា "នាងនោះត្រូវបានទៅព្រាហ្មណ៍ដែលសង់ខ្ទមសំណាក់នៅក្នុងទីប៉ាឆានោះ" ។

អារក្សថា "បើព្រាហ្មណ៍ម្នាក់មិនបានរក្សាធាតុនាងទុក ទាំងព្រាហ្មណ៍ទី ២ ក៏មិនបានចេះមន្តប្រោះមក តើនារីនោះអាចរស់ឡើងដូចម្តេចបាន?" ។

ព្រះរាជាត្រាស់ថា "អ្នកដែលទុកធាតុ គឺបានបំពេញករណីយកិច្ចខ្លួន ក្នុងឋានៈជាបុត្រ, - អ្នកដែលបានប្រោះជីវិតរស់ទុកជាឪពុករបស់នាង, អ្នកដែលបានប្រមូលផេះធាតុ ទាំងបានសង់ខ្ទមនៅក្នុងទីនោះផង ត្រូវបាននាងជាភរិយា" ។

អារក្សបានឮព្រះមហាក្សត្រិយ៍តបដូច្នេះ ក៏ហោះត្រឡប់ទៅឯដើមឈើរបស់ខ្លួនវិញ ។ ព្រះរាជាក៏ស្តេចទៅតាមចាប់អារក្សនោះបែកថង់យាមពាក់លើព្រះអង្គ ហើយយាងមកវិញ ។

(មានត)

## អនិច្ចកម្មនៃព្រះធេពមុនី យូរ-ប៉ុណ្ណ

## ព្រះទេពសត្ថា ស្បូ-បាយ

### ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

### រៀបរៀង

ព្រះទេពមុនី យូរ-ប៉ុណ្ណ វត្តឧណ្ណាលោម ជាកជាគណៈថ្នាក់ទី ៤ ទទួលអនិច្ចធម្មនៅថ្ងៃអាទិត្យ ៤ កើតខែស្រាពណ៍ ព.ស. ២៤៩៤ (១៩ សីហា ១៩៥១) វេលាម៉ោង ១១ និង ៤០ នាទី ដោយកេតបេះដូងពិការ (ខ្យល់ចាប់) ។

ពុទ្ធបរិស័ទទាំងបព្វជិតទាំងគ្រហស្ថ មានសម្ដេចព្រះមហាសុមេធាធិបតីសង្ឃនាយកព្រះនាម ជួន-ណាត ជាប្រធាន បានរៀបចំដំកល់សពព្រះទេពមុនីទុក ៧ ថ្ងៃ នៅលើកុដិចាស់របស់សម្ដេច ដើម្បីធ្វើទក្ខិណានុប្បទានរៀងរាល់ថ្ងៃរាល់យប់ គឺៈពេលថ្ងៃ និមន្តព្រះសង្ឃចំនួន ៦០ អង្គ ទទួលសង្ឃភត្ត, បង្សុកូល; ពេលយប់ និមន្តព្រះធម្មថិកសំដែងធម៌ទេសនា ដាក់ទគ្សោសនស័ព្ទ គ្រឿងបំពងសំឡេង ។

កន្លែងដំកល់សពនោះ មានគ្រឿងប្រទីបផ្កាលា មានការតាក់តែងភ្លើងដោយពណ៌ ៩ មានភ្លើងពណ៌ខៀវជាដើម ព្រមទាំងគ្រឿងគន្ធមាលាផ្កាភ្ញីផ្សេងៗ អំពូលភ្លើងព័ទ្ធជុំវិញការម្ឈូស ។

ធ្វើឈាបនកិច្ច (បូជាសព) នៅថ្ងៃសៅរ៍ ៨ កើតខែស្រាពណ៍នោះ, វេលាម៉ោង ៤ រសៀល ព្រះសង្ឃរាជាគណៈ ឬ ជានាទុក្រម កិតុសាម-ណេរចំនួន ៨០០ អង្គ ក្នុងវត្តខណ្ឌណោមខ្លះ វត្តឯទៀតខ្លះ ព្រមទាំងអស់លោក អ្នកសប្បុរសជាគ្រហស្ថ បានមកជួបជុំគ្នាដង្ហែសពអំពីកុដិយកទៅដំកល់លើបារាំកំពូលដែលរចនាដ៏វិចិត្រនៅមុខវិហារវត្តខណ្ឌណោម ។ ក្នុងឱកាសបូជាសពនេះមានពុទ្ធបរិស័ទជាច្រើននាក់ មានឯកឧត្តម ហ៊ុយ-កន្ធុល អតីតរដ្ឋមន្ត្រី, លោកអ៊ូ-គង់ទីប្រឹក្សាព្រះរាជអាណាចក្រ ព្រមទាំងអស់លោក-អ្នកក្នុងក្រសួងពុទ្ធសាសនបណ្ឌិត្យ, ក្រសួងធម្មការ និងសាលាបាលីជាន់ខ្ពស់ជាដើម បានអញ្ជើញទៅជួយខ្វល់ខ្វាយអនុមោទនាដោយសេចក្ដីសោមនស្ស ។ លុះដំកល់សពលើបារាំកំពូលរួចហើយ ទើបនិមន្តព្រះសង្ឃ ១០០ អង្គបង្សុកូល, បន្ទាប់មកព្រះពោធិវង្ស (ហួត-តាត) ថ្លែងសេចក្ដីស្ដាយស្រណោះចំពោះព្រះទេពមុនីដោយសេចក្ដីសង្ខេប ។ បន្ទាប់មកទៀត លោកញ៉ង-សៀង ថ្លែងសុន្ទរកថា ក្នុងនាមពុទ្ធសាសន-បណ្ឌិត្យ ក្រុមជំនុំព្រះត្រៃបិដក និងសាលាបាលីជាន់ខ្ពស់ រៀបរាប់អំពីប្រវត្តិរូប និងកិត្តិគុណនៃព្រះទេពមុនី ដោយសេចក្ដីពិស្ដារ ។

ក្នុងឱកាសកំពុងបូជាសពនោះ បានប្រគេនចែកសៀវភៅធីរណ-កថាជាធម្មទាន ចំនួន២.០០០សៀវភៅ ដល់បព្វជិតនិងគ្រហស្ថ ដើម្បីឧទ្ទិសកុសលធម្មទាន ប្រគេនចំពោះវិញ្ញាណក្ខន្ធនៃព្រះទេពមុនី ។

# សុន្ទរកថាដែលលោក ញុង-សឿង ថ្លែង

សម្តេច !

ព្រះករុណា គ្រប់អង្គ !

ព្រះតេជព្រះគុណនិងអស់លោក-អ្នកពុទ្ធបរិស័ទទាំងឡាយ !

ខ្ញុំព្រះករុណា ខ្ញុំបាទ ជាតំណាងនាមនៃព្រះថេរានុត្ថេរៈគ្រប់អង្គ, អស់លោក-អ្នកក្រសួងពុទ្ធសាសនបណ្ឌិត្យ, អស់លោកជាសមាជិកក្រុមជំនុំព្រះត្រៃបិដក និងលោកគ្រូ សាស្ត្រាចារ្យសាលាបាលីជាន់ខ្ពស់ ដែលបានអនុញ្ញាតឲ្យខ្ញុំព្រះករុណា ខ្ញុំបាទ ថ្លែងរៀបរាប់ប្រវត្តិរូបនិងកិត្តិគុណ ព្រមទាំងសេចក្តីសោកស្តាយ ចំពោះព្រះទេពមុនី យូរ-ប៉ុណ្ណ ដែលជាសមាជិកនៃក្រុមជំនុំព្រះត្រៃបិដក ព្រមទាំងការចូលកាន់មរណសញ្ញា ចំពោះវិញ្ញាណក្ខន្ធរបស់ព្រះថេរៈអង្គនេះ ដូចសេចក្តីតទៅ ៖

## ប្រវត្តិរូបព្រះទេពមុនី យូរ-ប៉ុណ្ណ

ព្រះទេពមុនី (ឥន្ទសុវណ្ណោ) យូរ-ប៉ុណ្ណ បិតានាមយូរ, មាតានាមទៀវ, កើតនៅថ្ងៃ៥ កើតខែបុស្ស ឆ្នាំខាលចត្វាស័ក ព.ស.២៤៤៤, គ.ស.១៩០២ ក្នុងឃុំកន្ទោរ ស្រុកកំពង់ត្រាច ខេត្តកំពត ។ កាលនៅពីកុមារ មាតាបិតាបាននាំយកទៅឲ្យនៅវត្តព្រៃទប់ ឃុំស្រុកខេត្តជាមួយគ្នា ដើម្បីឲ្យសិក្សាអក្សរសាស្ត្រខ្មែរតាមសម័យនិយម ក្នុងសំណាក់លោកគ្រូមេគណព្រះនាម មិន ។ កុមារយូរ-ប៉ុណ្ណ បានទទួលការសិក្សាអក្សរ,

លេខនព្វន្តល្មមមើលបាន សរសេរកើត ព្រមទាំងធម៌អាថ៌ ។ លុះដល់អាយុ ១៣ ឆ្នាំ មាតាបិតាឲ្យបួសជាសាមណេរក្នុងវត្តព្រៃទប់នោះ, លោកគ្រូមេគណព្រះនាម មិន ជាព្រះឧបជ្ឈាយ៍ ។ កុមារ យូរ-ប៉ុណ្ណ បានទទួលបព្វជ្ជាជាសាមណេរ នៅថ្ងៃ ១៥ កើតខែពិសាខ ឆ្នាំខាលឆស័ក ព.ស. ២៤៥៦ ។ លុះដល់អាយុ ១៧ ឆ្នាំ ទើបលាចាកសិក្ខាបទពីសាមណេរ ។

បណ្ឌិតយូរ-ប៉ុណ្ណមានអាយុ ២១ ឆ្នាំ បានទទួលឧបសម្បទាជាភិក្ខុ ក្នុងព័ទ្ធសីមាវត្តអង្គសុរភី ឃុំកន្ទោរនោះដែរ ។ មាននាមឆាយា ឥន្ទសុវណ្ណោ នៅថ្ងៃ ១៥ កើតខែទុតិយាសាឍឆ្នាំចបញ្ចស័ក ព.ស. ២៤៦៥, គ.ស. ១៩២៣, ព្រះបាឡាត់រតនមុនីសាគរ (ណាវ-ទិត) ជាព្រះឧបជ្ឈាយ៍, ព្រះសុវណ្ណត្ថេរ (ឈួក-សំ) ជាកម្មវាចាចារ្យ, ព្រះចន្ទត្ថេរ (ម៉ុម-សួរ) ជាអនុសាវនាចារ្យ ។

ភិក្ខុ យូរ-ប៉ុណ្ណ នៅក្នុងសំណាក់ព្រះឧបជ្ឈាយ៍បាន ២ វស្សាក៏លាលោកគ្រូព្រះឧបជ្ឈាយ៍ លោកគ្រូសូត្រ មកសិក្សាព្រះបរិយត្តិធម៌នៅវត្តវិហារត្រាញ់ ឃុំព្រែកស្ដែង ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល, រៀនព្រះបរិយត្តិធម៌ក្នុងសំណាក់លោកគ្រូអាចារ្យព្រះនាម ប៉ុល-គង់ ជាចៅអធិការវត្តនោះ ។ ភិក្ខុ យូរ-ប៉ុណ្ណ បាននៅសំណាក់អាស្រ័យសិក្សាព្រះបរិយត្តិធម៌ក្នុងវត្តវិហារត្រាញ់នោះបាន ៤ វស្សា, បានរៀនចប់គម្ពីរ

ធម្មបទដ្ឋកថាដោយសព្វគ្រប់ រួចលោកគ្រូអាចារ្យវត្តនោះ ត្រឡប់ទៅនៅឯវត្តស្រុកកំណើតរបស់ខ្លួនវិញ, បានទៅបង្រៀនសាស្ត្រាបាលីកិច្ច-សាមណេរឯវត្តអង្គស្សុរកីបាន ២ វស្សា ទើបលោកគ្រូចៅអធិការព្រះនាម ពៅ-ង៉ែត មកឯក្រុងភ្នំពេញ ។ ក្នុងកាលនោះលោកគ្រូចៅអធិការ ពៅ-ង៉ែត បាននាំលោកអាចារ្យ យូរ-ប៉ុណ្ណ មកផ្ញើផ្ដាក់ឲ្យនៅក្នុងសំណាក់សម្ដេចព្រះមហាសុមេធាធិបតី កាលនៅជាព្រះសាសនសោភ័ណ ។ សម្ដេចបានទទួលឲ្យនៅក្នុងកុដិជាមួយ ដោយសេចក្ដីអនុគ្រោះ ។ អាចារ្យ យូរ-ប៉ុណ្ណ បានប្រឡងប្រជែងយកថ្នាក់រៀនក្នុងសាលាបាលីជាន់ខ្ពស់ពី គ.ស. ១៩៣៥, ប្រឡងចេញពី គ.ស. ១៩៣៨ បានសញ្ញាប័ត្រសាលាបាលីជាន់ខ្ពស់ ។ ក្នុងឆ្នាំ ១៩៣៨ នេះក៏បានធ្វើជាក្រុមជំនុំព្រះត្រៃបិដក; បន្ទាប់មកបានឡើងសមណស័ក្តិជាព្រះសមុហ៍ឃោសាចារ្យ របស់សម្ដេចព្រះមហាសុមេធាធិបតី សង្ឃនាយក កាលនៅជាព្រះពុទ្ធឃោសាចារ្យ, តមកបានឡើងជាព្រះបាឡាត់ពោធិកមរបស់សម្ដេច កាលនៅជាព្រះពោធិវ័ង្ស, លំដាប់មកទៀត បានឡើងជាព្រះវិនយធម្ម សម្រាប់វត្តឧណ្ណាលោម; ក្រោយមកទៀត បានឡើងសមណសក្តិទីជារាជាគណៈថ្នាក់ទី ៤ ដោយព្រះរាជក្រឹត្យលេខ ១ ប៉. រ. ចុះថ្ងៃទី ២១ ខែឧសភា គ. ស. ១៩៤៨ ។

ព្រះទេពមុនី (យូរ-ប៉ុណ្ណ) ជាសមាជិកនៃក្រុមជំនុំព្រះត្រៃបិដក ជាសមាជិកនៃថេរសភាជាន់ខ្ពស់, ជាសមាជិកនៃក្រុមជំនុំប្រឡងសិស្ស

សាលាបាលីរេននឹងសាលាបាលីជាន់ខ្ពស់ ទាំងប្រឡងចូលនិងប្រឡងចេញ, ជាសមាជិកនៃគណៈកម្មការតែងធម្មវិន័យ ។ ព្រះថេរៈអង្គនេះបានបំពេញកិច្ចការដែលត្រូវធ្វើ ដោយយកចិត្តទុកដាក់ឥតធ្វេសប្រហែសឥតខ្វាចនៀយហត់ ។ ដល់មកថ្ងៃអាទិត្យ ២ កេចខែស្រាពណ៍ (១៩ សីហា គ.ស. ១៩៥១) វេលាម៉ោង ១១ និង ៤០ នាទី ទទួលអនិច្ចធម្មដោយស្ងប់ស្ងៀម នៅលើកុដិតូចរបស់លោក ដោយរោគរបេះដូងពិការ (រោគខ្យល់ចាប់) ក្នុងគំរប់ជន្មាយុ ៥០ ឆ្នាំ ។

## កិត្តិគុណព្រះទេពមុនីយូរ - ប៉ុណ្ណ និងសេចក្ដីស្ដាយនៃក្រុមជំនុំព្រះត្រៃបិដក

ព្រះករុណាគ្រប់អង្គ !

អស់លោក - អ្នកពុទ្ធបរិស័ទទាំងឡាយ !

ព្រះទេពមុនី យូរ - ប៉ុណ្ណនេះ ជាបណ្ឌិតដែលមានសណ្ដាប់ធ្នាប់ល្អគួរគាប់ថាជាអ្នកប្រាជ្ញមួយរូបខាងពុទ្ធសាសនា ក្នុងចំណោមអ្នកប្រាជ្ញទាំងឡាយ ។ ព្រះថេរៈអង្គនេះ មានចំណេះចេះដឹងរបៀបវេយ្យាករណ៍ភាសាបាលី ព្រមទាំងធម៌វិន័យដោយហ្មត់ចត់, ជាធម្មកថិកអាចចេះសំដែងធម៌ទេសនាទូន្មានពុទ្ធបរិស័ទបាន, ជាអ្នកមានសមត្ថភាពខាងធម៌អាថ៌និងកិច្ចការទាំងពួង, បានទទួលទេសនាផ្សាយតាមវិទ្យុកម្មជាក្នុងក្រសួងឃោសនាការជាញឹកញយ ។ ព្រះទេពមុនី ជាព្រះថេរៈប៉ុន

ប្រសប់, មានព្យាយាមក្នុងការតែងធម៌គាថផ្សេងៗ ចុះក្នុងសៀវភៅទស្សនាវដ្ដី កម្ពុជសុរិយា ដើម្បីផ្សាយព្រះពុទ្ធសាសនានិងអក្សរសាស្ត្រជាច្រើនៗ ។ ព្រះថេរៈអង្គនេះ ឈ្មោះថាជាកម្លាំងដ៏មាំមួនរបស់ពុទ្ធ-សាសនបណ្ឌិត្យផង របស់វត្តឧណ្ណាលោមនេះផង ។

ព្រះទេពមុនី! ព្រះគុណទទួលអនិច្ចធម្មនិមន្តទៅកាន់បរលោកនាយ បោលកិច្ចការពុទ្ធសាសនាអស់ហើយ ។ កិច្ចការទាំងនោះ យើងខ្ញុំទាំងឡាយនឹងទទួលកាប់រងធ្វើជំនួស, សូមព្រះគុណម្ចាស់កុំព្រួយព្រះទ័យ, សូមនិមន្តទៅកាន់បរលោកនាយដោយសុវត្ថិភាពចុះ, ព្រោះថាព្រះគុណម្ចាស់ត្រូវទទួលវេនរបស់មច្ចុសង្គ្រាមហើយ, សូមកុំតូចព្រះទ័យចំពោះដំណើរទៅកាន់បរលោកនាយនេះឲ្យសោះ ព្រោះព្រះគុណម្ចាស់បានបំពេញករណីយកិច្ចក្នុងព្រះពុទ្ធសាសនា ព្រមទាំងសង្គ្រោះញាតិមិត្រសិស្សគណដោយសព្វគ្រប់ហើយ ទាំងការបំរើព្រះពុទ្ធសាសនាក៏បានប្រគល់កាយថ្វាយខ្លួនជាបព្វជិត បូជាព្រះពុទ្ធសាសនាផ្ទាល់ខ្លួនហើយ ។ ព្រះទេពមុនី! ជីវិតរបស់ព្រះគុណម្ចាស់ ឈ្មោះថាជាជីវិតមានភ័ព្វណាស់, ជាជីវិតមានខ្លឹមសារប្រកបដោយឧត្តមគតិ ដែលគួរឲ្យបព្វជិតយកតម្រាប់តាមបាន, ជាជីវិតមានសារៈប្រយោជន៍ក្នុងព្រះពុទ្ធសាសនាដោយការបំរើព្រះពុទ្ធសាសនាផ្ទាល់ខ្លួនពេញកំឡាំងជាបមកហើយ ។

អស់លោក-អ្នកទាំងឡាយ !

រូបជីវិតរបស់ព្រះថេរៈអង្គនេះ ទោះបីបាត់បង់ទៅក៏ពិតមែន តែកិត្តិ-គុណគឺកេរ្តិ៍ឈ្មោះល្អរបស់លោក មិនអាចបាត់បង់សាបសូន្យទៅឡើយ ។ ព្រះថេរៈអង្គនេះ មានជីវប្រវត្តិ និងកិត្តិគុណ ដែលគួរពុទ្ធបរិស័ទស្តាយ អាល័យជាទីបំផុត ។ ប្រវត្តិរូបនិងកិត្តិគុណដែលយើងខ្ញុំបានថ្លែងមកនេះ ទុកជាអនុស្សាវរីយ៍មួយរបស់ពុទ្ធសាសនិកជនតទៅ, ព្រោះព្រះទេពមុនី ទទួលអនិច្ចធម្មទៅ តែរូបកាយប៉ុណ្ណោះទេ, ឯគ្រឿងនាមនិងគោត្រគឺកេរ្តិ៍ ឈ្មោះល្អរបស់លោក មិនបានទទួលអនិច្ចធម្មទៅផងឡើយ ។

មន្ទីរក្រុមជំនុំព្រះត្រៃបិដក ដែលធ្លាប់តែមានព្រះថេរៈអង្គនេះគង់នៅធ្វើការជាមួយគ្នានឹងយើងខ្ញុំ, ជាទីសប្បាយរីករាយ; ព្រះថេរៈអង្គនេះ ជាគូប្រឹក្សាជាមួយគ្នា នាំឲ្យក្តីគំនិតប្រាជ្ញា ឥឡូវនេះក្រសួងនេះខាតគូប្រឹក្សាមួយរូប, វត្តខុណ្ណាលោមនេះក៏ឈ្មោះថាខាតមហាថេរមួយអង្គដែរ ដែលនាំឲ្យខ្សោយស័ព្ទអន់ស្រពោន ដូចជាពពកមួយផ្ទាំងបាំងពន្លឺព្រះអាទិត្យ ព្រះចន្ទ ឲ្យអន់ស្រពោន គឺជានាំឲ្យយើងខ្ញុំមានអាការរហេងរហាងដួលក្នុងចិត្ត ស្មើរតែគ្រប់ ៗ គ្នា ។

មច្ចុរាជដែលប្រើអំណាចចំលោក ដណ្តើមយកជីវិតិន្ទ្រិយរបស់ព្រះទេពមុនីនេះ មិនមែននាំឲ្យយើងគ្រាន់តែខាតបង់បុគ្គលិកក្នុងក្រសួងឬ ក្នុងវត្តប៉ុណ្ណោះទេ គឺឈ្មោះថាមច្ចុរាជនេះ ជាអ្នកបំផ្លាញកិច្ចការផ្សេង ១

របស់មុខក្រសួងផង របស់ផ្ទាល់ខ្លួនផង ។ ក្រុមជំនុំព្រះត្រៃបិដកខាតសមាជិកមួយរូប ជាជំនួយក្នុងកិច្ចការដែលត្រូវធ្វើតទៅទៀត ។ ការបាត់បង់សហការីបុគ្គលនេះ នាំឲ្យយើងខ្ញុំក្នុងក្រសួងជាមួយគ្នា មានសេចក្តីទុក្ខតានតឹងស្តាយស្រណោះជាទីបំផុត ។

ពេលនេះពុទ្ធបរិស័ទទាំងឡាយ ទាំងបព្វជិតទាំងគ្រហស្ថ បានមកប្រជុំគ្នាធ្វើឈាបនកិច្ច (បូជាសព) ព្រះទេពមុនី ។ មុនអំពីការបូជានេះ យើងខ្ញុំថ្លែងប្រវត្តិរូបនិងកិត្តិគុណ ព្រមទាំងសេចក្តីសោកស្តាយ ដោយយើងខ្ញុំដែលធ្លាប់ស្គាល់ជាក់លាក់ បានចាំរូបរាងទ្រង់ទ្រាយព្រះភក្ត្រនិងសំដីឥតភ្លេចសោះ នឹកឡើងហាក់ដូចជាឃើញកំពុងតែអង្គុយលើកៅអីសរសេរធ្វើការជាមួយគ្នា ។ ព្រះសង្ឃវត្តនេះ មានសម្តេចជាប្រធាន, កាលបើឥតអំពីព្រះទេពមុនីនេះ, ក៏មានសេចក្តីស្តាយស្រណោះរហោងរហាងក្នុងព្រះទ័យ ។ ព្រះថេរៈអង្គនេះមានសេចក្តីប្រកាន់តាមច្បាប់បញ្ញត្តិរបស់ក្រសួងដោយទៀងទាត់ អំពីម៉ោងពេលដែលចេញចូលធ្វើការ, ព្រះថេរៈអង្គនេះ មុនអំពីទទួលអនិច្ចធម្ម បានបំពេញករណីយកិច្ចរបស់សមណភាពផ្ទាល់ខ្លួន ព្រមទាំងរបស់មនុស្សជាតិដ៏ពេញបរិបូណ៌សមគួរហើយ ។

ក្នុងឱកាសដំកល់សពនិងវេលាធ្វើឈាបនកិច្ចនេះ ពុទ្ធបរិស័ទបានធ្វើកាម៉េសតាននឹងធម្មទានគ្រប់ទិវារាត្រី ដើម្បីជាទក្ខិណានុប្បទាន ចំពោះ

ព្រះទេពមុនី បានតាំងបោះពុម្ពសៀវភៅធម៌ ប្រគេនចែកជាធម្មទាន ចំពោះបព្វជិតនិងគ្រហស្ថ ដែលបាននិមន្តបានអញ្ជើញមកជួយឧបត្ថម្ភ ខ្វល់ខ្វាយក្នុងបុណ្យនេះ ។ សូមប្រមូលបុញ្ញាកសីទាំងនេះ ទុកជាបណ្ណាការដ៏ប្រសើរ ឧទ្ទិសចំពោះព្រះទេពមុនី ។

ទីបំផុតនេះ សូមពុទ្ធបរិស័ទទាំងឡាយ តាំងចិត្តខមាទោសនិងឧទ្ទិសបុណ្យកុសលចំពោះព្រះទេពមុនីឲ្យគ្រប់ៗគ្នា !

ព្រះទេពមុនី យូរ-ប៉ុណ្ណ ! យើងខ្ញុំទាំងឡាយសូមខមាទោសចំពោះព្រះគុណម្ចាស់ ដោយហេតុក្រែងយើងខ្ញុំមានសេចក្ដីធ្គាំធ្គងលើសលោះដោយកាយវាចាចិត្ត, ដូច្នេះ សូមព្រះគុណម្ចាស់ឲ្យអភ័យអត់ទោសកំហុសនោះឲ្យទាន ។

យើងខ្ញុំជាពុទ្ធបរិស័ទ សូមប្រគេនបុណ្យកុសល ដោយចេតនាដ៏បរិសុទ្ធ ! សូមព្រះគុណម្ចាស់អនុមោទនាទទួលយកដោយសេចក្ដីសោមនស្សឲ្យទាន ! ហើយសូមឲ្យព្រះគុណម្ចាស់ បានប្រកបដោយសុខភាព-វឌ្ឍនភាព មានជ័យមង្គលគ្រប់ប្រការ ក្នុងជីវិតថ្មីរបស់ព្រះគុណម្ចាស់ តាមសេចក្ដីប្រាថ្នាតរៀងឆ្ងាយទៅ ! ។